- ត្រីកោណ AQF : $A + F + Q_2 = 180°$ (2)
- ត្រីកោណ CBP : $B + C + P_2 = 180°$ (3)

$P_1 + P_2 = 180°$

$Q_1 + Q_2 = 180°$

បូកអង្គនិងអង្គ (1), (2) និង (3) :

$$A + B + C + D + E + F = 360°$$

{ - គូររូប 10, - ។ 0 }

**II.** (ពិន្ទុ 15)

- យក $x = \frac{n(n+1)}{2}$ និង $y = \frac{n(n-1)}{2}$, $n \in N$ ] 10

បើ n ជាចំនួនគត់សេស នោះ n+1 និង n-1 ចែកដាច់នឹង 2

បើ n ជាចំនួនគត់គូ នោះ n ចែកដាច់នឹង 2

ដូចនេះ x និង y ជាចំនួនគត់ ] 5

- ផ្ទៀងផ្ទាត់ :

$$x^2 - y^2 = \frac{n^2}{4}\left[(n+1)^2 - (n-1)^2\right]$$

$$= \frac{n^2}{4} \cdot 2n \cdot 2$$

$$= n^3$$

10 + បរិយាយគ្រប់ 5



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

(III). (ពិន្ទុ 20)




រក $\widehat{AEB}$ :

តាង $a$ ជារង្វាស់ជ្រុងការេ

គេបាន $x^2 + y^2 = 1$ (1)

$(a-x)^2 + y^2 = 4$ (2)

$(a-x)^2 + (a-y)^2 = 9$ (3) — 5 ពិន្ទុ

(1) ជំនួស (2) : $(a-x)^2 + 1 - x^2 = 4$

$x = \frac{a^2-3}{2a}$

(2) ជំនួស (3) : $4 - y^2 + (a-y)^2 = 9$

$y = \frac{a^2-5}{2a}$

(1) : $\left(\frac{a^2-3}{2a}\right)^2 + \left(\frac{a^2-5}{2a}\right)^2 = 1$

$a^4 - 10a^2 + 17 = 0$

$a^2 = 5 - 2\sqrt{2}$ មិនយក ព្រោះនាំឲ្យ $x<0, y<0$

$a^2 = 5 + 2\sqrt{2}$ យក — 10 ពិន្ទុ

ទ្រឹស្តីបទកូស៊ីនុសក្នុងត្រីកោណ AEB :

$5 + 2\sqrt{2} = 1^2 + 2^2 - 2 \times 1 \times 2 \cos \widehat{AEB}$

$\cos \widehat{AEB} = \frac{-1}{\sqrt{2}}$ នាំឲ្យ $\boxed{\widehat{AEB} = 135^\circ}$ 5 ពិន្ទុ

ដូច្នេះ ក្រឡាផ្ទៃការេ : $\boxed{5 + 2\sqrt{2} \text{ ឯកតាក្រឡាផ្ទៃ}}$



www.pisethsok.wordpress.com
សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

III (ពិន្ទុ 25)

$$f(n+1) = 2f(n) - f(n-1) + n + 1$$

ទាញបាន: $f(n+1) - f(n) = f(n) - f(n-1) + n + 1$

$$f(n) - f(n-1) = f(n-1) - f(n-2) + n$$

$$\cdots\cdots\cdots$$

$$f(3) - f(2) = f(2) - f(1) + 3$$

$$f(2) - \underbrace{f(1)}_{0} = f(1) - \underbrace{f(0)}_{0} + 2$$

បូក: $f(n+1) = f(n) + (n+1) + n + \cdots + 3 + 2$

$$f(n+1) - f(n) = \frac{1}{2} n \left[ (n+1) + 2 \right]$$

$$f(n+1) - f(n) = \frac{1}{2} n(n+3) \quad (1) \quad \text{-- 7 pts}$$

តាម (1): $f(n+1) - f(n) = \frac{1}{2} n(n+3)$

$$f(n) - f(n-1) = \frac{1}{2}(n-1)(n+2)$$

$$\cdots\cdots\cdots$$

$$f(3) - f(2) = \frac{1}{2} \times 2 \times 5$$

$$f(2) - \underbrace{f(1)}_{0} = \frac{1}{2} \times 1 \times 4$$

បូក: $f(n+1) = \frac{1}{2}\left[ n(n+3) + (n-1)(n+2) + \cdots + 2\times 5 + 1\times 4 \right]$ 7 pts

$$= \frac{1}{2}\left( \sum_{p=1}^{n} p^2 + \sum_{p=1}^{n} 3p \right)$$

$$= \frac{1}{2}\left[ \frac{1}{6} n(n+1)(2n+1) + 3 \times \frac{1}{2} n(n+1) \right]$$

សំរាយ $\sum p$ 3 pts

$$f(n+1) = \frac{1}{6} n(n+1)(n+5) \quad \text{-- 7 pts}$$

ជំនួស $n$ ដោយ $n-1$

$$\boxed{f(n) = \frac{1}{6}(n-1)n(n+4)} \quad \text{-- 4 pts}$$

www.pisethsok.wordpress.com

(ទំ. 30)

យើងត្រូវបង្ហាញថា:

- បើ $\sqrt{a} \in \mathbb{Q}$ នោះ $a$ ជាការេប្រាកដ
- បើ $\sqrt{a}+\sqrt{b} \in \mathbb{Q}$ នោះ $a$ និង $b$ ជាការេប្រាកដ
- បើ $\sqrt{a}+\sqrt{b}+\sqrt{c} \in \mathbb{Q}$ នោះ $a, b$ និង $c$ ជាការេប្រាកដ

ក) បើ $\sqrt{a} \in \mathbb{Q}$

តាង $\sqrt{a} = \frac{p}{q}$ , $p$ និង $q$ ជាចំនួនគត់វិជ្ជមានដែលបឋមរវាងគ្នា

តាមស.ក. $a$ ជាចំនួនគត់វិជ្ជមាន

ដោយ $p$ និង $q$ បឋមរវាងគ្នា

ដូចនេះ $a$ ជាចំនួនគត់វិជ្ជមានកាលណា $q^2=1$

យើងបាន $a=p^2$ ជាការេប្រាកដ។

ខ) បើ $\sqrt{a}+\sqrt{b} \in \mathbb{Q}$

តាង $\sqrt{a}+\sqrt{b} = r$ , $r \in \mathbb{Q}$

បើ $r=0$ នោះ $a=b=0$ ផ្ទុយស.ក.

ដូចនេះ $r \neq 0$

$\sqrt{b} = r-\sqrt{a}$ ; $b = r^2-2r\sqrt{a}+a$

$\sqrt{a} = \frac{r^2+a-b}{2r} \in \mathbb{Q}$

តាម ក) $a$ ជាការេប្រាកដ

ស្រដៀងគ្នាដែរយើងបាន $\sqrt{b} = \frac{r^2+b-a}{2r} \in \mathbb{Q}$

តាម ក) $b$ ជាការេប្រាកដ

គ) បើ $\sqrt{a}+\sqrt{b}+\sqrt{c} \in \mathbb{Q}$

តាង $\sqrt{a}+\sqrt{b}+\sqrt{c} = \frac{p}{q}$ , $\frac{p}{q} \in \mathbb{Q}$ , $a, b, c, p, q$ គត់វិជ្ជមាន

យើងបាន $q\sqrt{a}+q\sqrt{b} = p-q\sqrt{c}$

លើកជាការេ: $2q^2\sqrt{ab}+2pq\sqrt{c} = p^2+q^2(c-a-b)$

$$\sqrt{4q^4ab}+\sqrt{4p^2q^2c} = p^2+q^2(c-a-b) \in \mathbb{Q}$$

តាម ខ) យើងបាន $4q^4ab$ និង $4p^2q^2c$ ជាការេប្រាកដ

ដូចនេះ $c$ ជាការេប្រាកដ

ស្រដៀងគ្នាដែរ:

$$\sqrt{4q^4ac}+\sqrt{4p^2q^2b} = p^2+q^2(b-a-c) \in \mathbb{Q}$$

$$\sqrt{4q^4bc}+\sqrt{4p^2q^2a} = p^2+q^2(a-b-c) \in \mathbb{Q}$$

តាម ខ) $b$ និង $a$ ជាការេប្រាកដ



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

(12) ហ៊ន ស៊ីពាន

**ប្រឡងជ្រើសរើសសិស្សពូកែគណិតវិទ្យាថ្នាក់ទី១២ ចំនួន ០៤រូប សំរាប់**
**ចូលរួមប្រឡងគណិតវិទ្យាអូឡាំពិច លើកទី៣ (១៩_២៣ ឧសភា ២០០៣)**
**សម័យប្រឡង : ០២_០១_០៣**
**រយៈពេល : ៣ម៉ោង (១០០ពិន្ទុ)**

វិញ្ញាសាសំរាប់ថ្ងៃទី២ :

I. (៥ពិន្ទុ) រកចំនួនពិតវិជ្ជមាន $x$ ដែលផ្ទៀងផ្ទាត់សមីការ $x.x^{\frac{3}{x}} = \frac{x^x}{x}$ ។

II. (១៥ពិន្ទុ)

១. $f$ ជាអនុគមន៍កំនត់ដោយ $f(n) = 3^{3n} + 7$ ដែល $n \in \mathbb{N}$ ។

បង្ហាញថា $f(n+1) - f(n)$ ចែកដាច់នឹង 8 ។

២. បង្ហាញថា $E = \frac{n}{3} + \frac{n^2}{2} + \frac{n^3}{6}$ (ដែល $n \in \mathbb{N}$ ) ជាចំនួនគត់ធម្មជាតិ។

III. (២៥ពិន្ទុ) $g$ ជាអនុគមន៍ ដែលបំពេញលក្ខណៈ ដូចខាងក្រោម :

(i) $g(n)$ កំនត់ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$

(ii) $g(n)$ ជាចំនួនគត់,

(iii) $g(2) = 2$

(iv) $g(mn) = g(m).g(n)$ ចំពោះគ្រប់ $m$ និង $n$

(v) $g(m) > g(n)$ បើ $m > n$

បង្ហាញថា $g(n) = n$ ចំពោះ $n = 1, 2, 3, \ldots$ ។

IV. (២៥ពិន្ទុ) $ABC$ ជាត្រីកោណកែង ត្រង់ $A$ ហើយមានកំពស់ $[AD]$។ រង្វង់ផ្ចិត $O_1$ និង $O_2$ ចារឹករៀងគ្នា ក្នុងត្រីកោណ $ABD$ និង $ACD$ ។ បន្ទាត់ $(O_1O_2)$ ជួបជ្រុង $[AB]$ និង $[AC]$ រៀងគ្នា ត្រង់ $K$ និង $L$ ។ តាង $S_1$ និង $S_2$ ជាផ្ទៃក្រលារៀងគ្នា នៃត្រីកោណ $ABC$ និង $AKL$ ។

បង្ហាញថា $S_1 \geq 2S_2$ ។

V. (៣០ពិន្ទុ) គេបានជំនួសលេខនីមួយៗដោយអក្សរ នៅក្នុងផលបូក ដូចខាងក្រោម :

```
  S E V E N
  S E V E N
+     S I X
-----------
T W E N T Y
```

រកលេខដែលត្រូវគ្នានឹងអក្សរនីមួយៗខាងលើ បើអក្សរនីមួយៗ តាងលេខខុសៗគ្នា ហើយ ខុសពីលេខ 9 ។



www.pisethsok.wordpress.com
សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

I (ពិន្ទុ 5)

$$\frac{x^2 \cdot x^{\frac{3}{x}}}{x^x} = 1$$

$$x^{2+\frac{3}{x}-x} = 1$$

$$x^{\frac{-x^2+2x+3}{x}} = 1$$

- បើ $x = 1$ នោះ $1^4 = 1$ ផ្ទៀងផ្ទាត់ — ត្រូវបាន 3 ពិន្ទុ 0
- បើ $x \neq 1$ នោះ $-x^2+2x+3 = 0$

$x = -1$ ; $x = 3$ (មិនយក)

ដូចនេះ សមីការមានឫស $x = 1$ ; $x = 3$

II (ពិន្ទុ 15)

1. (ពិន្ទុ 5)

$$f(n+1) - f(n) = \left(3^{2(n+1)} + 7\right) - \left(3^{2n} + 7\right)$$
$$= 3^{2n+2} - 3^{2n}$$
$$= 3^{2n}\left(3^2 - 1\right)$$
$$= 8 \cdot 3^{2n}$$

ដូចនេះ: $f(n+1) - f(n)$ ចែកដាច់នឹង 8 — ត្រូវ 5 ពិន្ទុ 0

2. (ពិន្ទុ 10)

$$E = \frac{n}{3} + \frac{n^2}{2} + \frac{n^3}{6}$$
$$6E = 2n + 3n^2 + n^3$$
$$= n(n^2 + 3n + 2)$$
$$= n(n+1)(n+2)$$

ដោយ $n$ ; $n+1$ ; $n+2$ ជាបីចំនួនគត់តគ្នា នោះគេបាន:

$n(n+1)(n+2)$ ចែកដាច់នឹង 2
$n(n+1)(n+2)$ ចែកដាច់នឹង 3 — មិនមានតួចែករួម

ពោលគឺ: $n(n+1)(n+2)$ ចែកដាច់នឹង $2 \times 3$ គឺ 6

ដូចនេះ: $6E$ ចែកដាច់នឹង 6 គឺ E ជាចំនួនគត់ធម្មជាតិ



www.pisethsok.wordpress.com
សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

III (ពិន្ទុ 25)

បង្ហាញថា $g(n) = n$ ចំពោះគ្រប់ $n = 1, 2, 3, \ldots$

+ $g(2) = g(1\cdot 2) = g(1)\cdot g(2)$

$2 = 2\cdot g(1)$ នាំឲ្យ $g(1) = 1$

ដូចនេះ៖ ទំនាក់ទំនងពិតចំពោះ $\underline{n = 1}$

+ ឧបមាថា ទំនាក់ទំនងពិតចំពោះ $n = k$

គេបាន $g(k) = k$

+ គេពិនិត្យចំពោះ $n = k+1$

• បើ $k+1 = 2l$ ដែល $1 \le l < k$

$g(k+1) = g(2l) = g(2)\cdot g(l)$ ព្រោះ $1 \le l < k$

$= 2l$

$g(k+1) = 2l = k+1$

• បើ $k+1 = 2l+1$ ដែល $1 \le l < k$

គេបាន៖

$2l = g(2l) < g(2l+1)$ ព្រោះ $2l < 2l+1$ (1)

ហើយ $g(2l+1) < g(2l+2)$ ព្រោះ $2l+1 < 2l+2$ (2)

តាម (1) & (2) : $2l < g(2l+1) < g[2(l+1)]$

$2l < g(2l+1) < g(2)\cdot g(l+1)$

$2l < g(2l+1) < 2(l+1)$

$2l < g(2l+1) < 2l+2$

ហើយ $g(2l+1)$ ជាចំនួនគត់

នាំឲ្យបាន $g(2l+1) = 2l+1$

$g(k+1) = k+1$

ដូចនេះ៖ ទំនាក់ទំនងពិតចំពោះ $n = k+1$

សន្និដ្ឋាន៖ $\boxed{g(n) = n \text{ ចំពោះ } n = 1; 2; 3; \ldots}$



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

(ពិន្ទុ25)




តាង $AB=c$ , $AC=b$ , $BC=a$ , $AD=h$

$R_1=$ កាំរង្វង់$(O_1)$ , $R_2=$ កាំរង្វង់$(O_2)$

គេបាន : $S_1=\frac{1}{2}ah$ (1)

$S_2=\frac{1}{2}AK.AL$ (2)

តែ : $AK=AE+EK=AF+EK$ (3) ព្រោះ : $AE=AF$

$AE=AF=AD-FD=h-R_1$ ព្រោះ : $O_1FDD'$ ជាការេជ្រុង $R_1$

$O_1I=O_1J-IJ=O_1J-O_2H$ ព្រោះ : $IJ=O_2H=R_2$

$=AE-O_2H$ ព្រោះ : $O_1J=AE$

$O_1I=h-R_1-R_2$ (4)

$O_2I=HJ=AH-AJ=AG-O_1E$ ព្រោះ : $AH=AG$ , $AJ=O_1E$

$O_2I=AG-O_1E$ (5)

តែ : $AG=AD-GD=h-R_2$ ព្រោះ : $GO_2D''D$ ជាការេជ្រុង $R_2$

(5) នាំឲ្យ $O_2I=h-R_2-R_1$ (6)

តាម (4)&(6) គេបាន $IO_1=IO_2=h-R_1-R_2$

ដូចនេះ : $\Delta IO_1O_2$ ជាត្រីកោណកែងសមបាតត្រង់ $I$ ហើយ $\widehat{IO_1O_2}=45^\circ$ 1ពិន្ទុ

គេទាញបាន $\widehat{EKO_1}=\widehat{IO_1O_2}=45^\circ$ (មុំត្រូវគ្នា)

ហើយ $\Delta EKO_1$ និង $\Delta AKL$ ជាកែងសមបាត

ទាំងនេះ : $EK=EO_1=R_1$ ; $AK=AL$ #

(3) : $AK=h-R_1+R_1=h$

(2) : $S_2=\frac{1}{2}h^2$

គេបាន : $\frac{S_1}{S_2}=\frac{ah}{h^2}=\frac{a}{h}=\frac{a^2}{ah}=\frac{b^2+c^2}{bc}$ ព្រោះ : $a^2=b^2+c^2$ ; $ah=bc$

$=\frac{b}{c}+\frac{c}{b}\geq 2$ នាំឲ្យ $\boxed{S_1\geq 2S_2}$ 15ពិន្ទុ

សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

V (ពិន្ទុ 30)

- គេគាត់សំគាល់ថា : $T = 1$ មិនមែន $T = 2$ (ព្រោះ: $S+S$ អាចមិនគ្រប់ អាចត្រាទុកមិនលើស 1)

បើ $T = 2$ លុះត្រាតែ $S = E = 9$ ផ្ទុយពីសម្មតិកម្ម (ស.ក. ... +9)

ដូចនេះ: $T = 1$ ទៅ

- ដើម្បីឲ្យ $T = 1$ លុះត្រាតែ $S \geq 5$

- បើ $x$ ជាលេខត្រាទុក ពីខ្ទង់ដប់ទៅខ្ទង់រយ នោះគេបាន:

$2E + x = 10a + E$ ដែល $0 \leq E < 9$ , $0 \leq a \leq 1$ , $0 \leq x \leq 2$

$E = 10a - x$

. បើ $a = 0$ នោះ: $E = -x$ ផ្ទុយពីសម្មតិកម្ម ( $E = 0$ នោះ: គ្មានI ; $E < 0$ )

. បើ $a = 1$ នោះ: $E = 10 - x$

+ បើ $x = 0$ នោះ: $E = 10$ មិនអាចបាន

+ បើ $x = 1$ នោះ: $E = 9$ មិនអាចបាន

+ បើ $x = 2$ នោះ: $E = 8$ ព្រោះពីខ្ទង់ដប់ទៅខ្ទង់រយត្រូវត្រាទុក 2

- ដោយ $E = 8$ នោះ: ត្រាទុកពីខ្ទង់ដប់ទៅខ្ទង់រយគឺ 1 ។

ម្យ៉ាងទៀត $S \geq 5$ (តាមសំរាយខាងលើ) ហើយ $S \neq 8$ និង $S \neq 9$

. បើ $S = 5$ នោះ: $S + S + 1 = 5 + 5 + 1 = 11$

គេបាន $W = 1$ ផ្ទុយពីសម្មតិកម្ម ព្រោះ: $T = 1$ រួចហើយ ។

. បើ $S = 7$ នោះ: គេបាន :

ឧបមាញត្រូវ
ប្រើលាយ tâtonner

គោល 10

$V \geq 6$ ហើយ $V \neq 7$ ; $V \neq 8$ ; $V \neq 9$ គឺ $V = 6$

+ បើ $V = 6$ នោះ: $N = 0$ ; $N = 1$ (+1 ត្រាទុកខ្ទង់10)

ករណី $N = 1$ មិនអាចយកបានទេ ព្រោះ: $T = 1$ រួចហើយ

ករណី $N = 0$ នោះ: $X = Y$ មិនអាចយកបានទេ ព្រោះ: $X \neq Y$

នោះបញ្ជាក់ថា $S = 7$ មិនអាចយកបានទេ គឺ $S = 6$ 3pts

- ដោយ $S = 6$ នោះ: គេបាន $W = 3$ 3pts ព្រោះ: $6 + 6 + 1 = 13$

- ដោយ $S = 6$ និង $N \neq 0$ ដើម្បីកុំឲ្យ ... 2 ... ខ្ទង់ 3



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

(5)

# ប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានីភ្នំពេញ

ថ្ងៃទី ០១ - ៤ - ២០០៣

វិញ្ញាសាទី១: គណិតវិទ្យាថ្នាក់ទី១២ រយៈពេល ៣ម៉ោង

ហ៊ិត ស៊ីវុទ្ធ
និពន្ធ: គណិតវិទ្យា
TEL: 011 953 029

20P I ក) គេអោយចំនួន $A = \underbrace{11\ldots11}_{n+1 \text{ តួនៃ } 1}$ $B = \underbrace{11\ldots11}_{2n \text{ តួនៃ } 1}$ $C = \underbrace{66\ldots66}_{n \text{ តួនៃ } 6}$

ស្រាយបញ្ជាក់ថា $A + B + C + 8$ ជាការេប្រាកដ ។

ខ) គណនាផលបូក $S = \sqrt{1+\frac{1}{1^2}+\frac{1}{2^2}} + \sqrt{1+\frac{1}{2^2}+\frac{1}{3^2}} + \ldots + \sqrt{1+\frac{1}{2002^2}+\frac{1}{2003^2}}$

20P II ក) គេអោយ $a, b, c$ ផ្ទៀងផ្ទាត់ $\begin{cases} a+b+c=0 \\ ab+bc+ca=0 \end{cases}$

គណនាតំលៃនៃកន្សោម $A = (a-1)^{2001} + b^{2002} + c^{2003}$

ខ) រក 11 ចំនួនមិនអវិជ្ជមាន ដែលចំនួននីមួយៗ ស្មើនឹងការេ នៃផលបូក 10 ចំនួនផ្សេងទៀត ។

10P III ស្រាយបញ្ជាក់ថា បើផលគុណឫសមួយនៃសមីការ $x^2 + ax + 1 = 0$ ជាមួយឫសណាមួយនៃសមីការ $x^2 + bx + 1 = 0$ ជាឫសនៃសមីការ $x^2 + abx + 1 = 0$ នោះ $\frac{4}{a^2b^2} - \frac{1}{a^2} - \frac{1}{b^2} = 2$

10P IV យក $a$ , $b$ , $c$ ជាប្រវែងជ្រុង និង $A, B, C$ ជាមុំនៃត្រីកោណ $ABC$ , $S$ ជាក្រលាផ្ទៃត្រីកោណ $ABC$ ។

ស្រាយបញ្ជាក់ថា $\cot A + \cot B + \cot C = \frac{a^2+b^2+c^2}{4S}$

10P V ស្រាយបញ្ជាក់ថាកន្សោម $10^n + 18n - 1$ ចែកដាច់នឹង 27 ចំពោះ $n$ ជាចំនួនគត់ធម្មជាតិ ។

30P VI ក) គេអោយជ្រុងនៃការេ $ABCD$ មានរង្វាស់ស្មើ 1 ។ នៅលើ ជ្រុង $[AB]$ , $[AD]$ គេដៅចំនុច $P$ និង $Q$ ដែលបរិមាត្រ ត្រីកោណ $APQ$ ស្មើ 2 ។ គណនា មុំ $\widehat{PCQ}$

ខ) គេអោយចតុកោណប៉ោង $ABCD$ មានក្រលាផ្ទៃ $S$ និងកន្លះបរិមាត្រ ស្មើ 2 ។

ស្រាយបញ្ជាក់ថា $S \leq 1$ ។

កម្រងវិញ្ញាសាទី 1

1.ក. (ចូរបង្ហាញថា) $A+B+C+8$ (10)

ដំណោះស្រាយ:

$$A = \underbrace{111\ldots1}_{(n+1)\text{ខ្ទង់}} = \frac{99\ldots9}{9} = \frac{10^{n+1}-1}{9}$$

$$B = \underbrace{11\ldots11}_{2n\text{ខ្ទង់}} = 10^{2n-1}+10^{2n-2}+\cdots+10+1 = \frac{10^{2n}-1}{9}$$

$$C = \underbrace{66\ldots66}_{n\text{ខ្ទង់}6} = 6\cdot\frac{10^{n}-1}{9}$$

ដូចនេះ: $A+B+C+8$

$$= \frac{10^{n+1}-1}{9} + \frac{10^{2n}-1}{9} + 6\cdot\frac{10^{n}-1}{9} + 8$$

$$= \frac{10\cdot10^{n} + 10^{2n} + 6\cdot10^{n} - 8 + 72}{9}$$

$$= \frac{1}{9}\left(10^{2n} + 16\cdot10^{n} + 64\right)$$

$$= \frac{1}{9}\left(10^{n}+8\right)^{2}$$

$$= \left(\frac{10^{n}+8}{3}\right)^{2} = \underbrace{33\ldots3}_{(n-1)\text{ខ្ទង់}3}6^{2}.$$

(10) គណនាផលបូក:

$$S = \sqrt{1+\frac{1}{1^2}+\frac{1}{2^2}} + \sqrt{1+\frac{1}{2^2}+\frac{1}{3^2}} + \cdots + \sqrt{1+\frac{1}{2002^2}+\frac{1}{2003^2}}$$

គេបាន: $$S = \sum_{n=1}^{2002}\sqrt{1+\frac{1}{n^2}+\frac{1}{(n+1)^2}}$$

$$S = \sum_{n=1}^{2002}\sqrt{\frac{n^4+2n^3+n^2+n^2+2n+1+n^2}{n^2(n+1)^2}}$$

$$= \sum_{n=1}^{2002}\sqrt{\frac{n^4+2n^3+3n^2+2n+1}{n^2(n+1)^2}}$$

$$= \sum_{n=1}^{2002}\sqrt{\frac{(n^2+n+1)^2}{n^2(n+1)^2}}$$

$$= \sum_{n=1}^{2002}\frac{n^2+n+1}{n(n+1)}$$

$$= \sum_{n=1}^{2002}\left(1+\frac{1}{n(n+1)}\right)$$

$$= 2002 + \sum_{n=1}^{2002}\left(\frac{1}{n}-\frac{1}{n+1}\right)$$

$$= 2002 + 1 - \frac{1}{2003}$$

$$\boxed{S = 2003 - \frac{1}{2003}} = \frac{2002\times2004}{2003}$$

20 II ក) គណនាតំលៃនៃ $A=(a-1)^{2001}+b^{2002}+c^{2003}$ (10)

ដឹងថា $a+b+c=0$; $ab+bc+ca=0$

នោះ: $(a+b+c)^2 = a^2+b^2+c^2+2(ab+bc+ca)$

នាំឲ្យ $a^2+b^2+c^2=0$

ឬ: $a=b=c=0$

ដូចនេះ: $A=(a-1)^{2001}+b^{2002}+c^{2003}$

$$\boxed{A=-1}$$

សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

(10) តាង $x_1, x_2, \dots, x_{11}$ ជាឫសប្រព័ន្ធ

ដែលការេនៃផលបូក ១០ ចំនួនផ្សេងទៀត:

$x_1 = (x_2+x_3+\dots+x_{11})^2$

$x_2 = (x_1+x_3+\dots+x_{11})^2$

គេបាន $x_1 - x_2 = (x_2+x_3+\dots+x_{11})^2 - (x_1+x_3+\dots+x_{11})^2$

$= (x_2-x_1)(x_2+x_1+2x_3+\dots+2x_{11})$

$(x_1-x_2)(1+x_2+x_1+2x_3+\dots+2x_{11})=0$

$x_1 = x_2$

តាមដំរូវនេះ គេបាន:

$x_1 = x_2 = \dots = x_{11} = x$

នាំ: $x = (\underbrace{x+\dots+x}_{10\text{ដង}})^2$

$x = 100x^2$

គេបាន: $x=0$ ឬ $x=\frac{1}{100}$

ស្រាយបញ្ជាក់ថា $\frac{1}{a^2b^2}-\frac{1}{a^2}-\frac{1}{b^2}=2$

តាង $\alpha, \beta$ រៀងគ្នាជាឫសសមីការ

$x^2+ax+1=0$ និង $x^2+bx+1=0$

ហើយ $\alpha\beta$ ជាឫសសមីការ

$x^2+abx+1=0$ នោះគេបាន

$\frac{1}{a^2b^2}-\frac{1}{a^2}-\frac{1}{b^2}=2$

គេមាន: $\alpha+\frac{1}{\alpha}=-a$ (1)

$\beta+\frac{1}{\beta}=-b$ (2)

$\alpha\beta+\frac{1}{\alpha\beta}=-ab$ (3)

(1) និង (2): $(\alpha+\frac{1}{\alpha})(\beta+\frac{1}{\beta})=ab$

$\alpha\beta+\frac{1}{\alpha\beta}+\frac{\alpha}{\beta}+\frac{\beta}{\alpha}=ab$

ជំនួស (3) បាន $\frac{\alpha}{\beta}+\frac{\beta}{\alpha}=2ab$ (4)

ម្យ៉ាងទៀត: លើកជាការេ (1), (2)

$$\begin{cases}\alpha^2+\frac{1}{\alpha^2}=a^2-2\\ \beta^2+\frac{1}{\beta^2}=b^2-2\end{cases}$$

គុណអង្គ: $\alpha^2\beta^2+\frac{1}{\alpha^2\beta^2}+\frac{\alpha^2}{\beta^2}+\frac{\beta^2}{\alpha^2}=(a^2-2)(b^2-2)$

តែ (3): $(\alpha\beta+\frac{1}{\alpha\beta})^2=a^2b^2$

$\alpha^2\beta^2+\frac{1}{\alpha^2\beta^2}=a^2b^2-2$

នាំអោយ $\frac{\alpha^2}{\beta^2}+\frac{\beta^2}{\alpha^2}=(a^2-2)(b^2-2)-a^2b^2+2$ (5)

តាម (4): $\frac{\alpha}{\beta}+\frac{\beta}{\alpha}=2ab$

$\frac{\alpha^2}{\beta^2}+\frac{\beta^2}{\alpha^2}=4a^2b^2-2$ (6)

(5) និង (6):

$4a^2b^2-2=(a^2-2)(b^2-2)-a^2b^2+2$

$4a^2b^2-2=a^2b^2-2a^2-2b^2+4-a^2b^2+2$

$4a^2b^2=8-2a^2-2b^2$

ចែកអង្គនឹង $2a^2b^2$

$2=\frac{4}{a^2b^2}-\frac{1}{b^2}-\frac{1}{a^2}$

www.pisethsok.wordpress.com

ស្រាយបញ្ជាក់ថា :

១) $\cot A + \cot B + \cot C = \dfrac{a^2+b^2+c^2}{4S}$



តាម ទ្រឹស្តីបទ Sinus:

$a^2 = b^2 + c^2 - 2bc\cos A$

$= b^2 + c^2 - 4\cdot\frac{1}{2}bc\sin A\cdot\frac{\cos A}{\sin A}$

$a^2 = b^2 + c^2 - 4S\cot A$

$b^2 = a^2 + c^2 - 4S\cot B$

$c^2 = a^2 + b^2 - 4S\cot C$

---

ដូច : $a^2+b^2+c^2 = 2(a^2+b^2+c^2) - 4S(\cot A+\cot B+\cot C)$

យ: $4S(\cot A+\cot B+\cot C) = a^2+b^2+c^2$

$\cot A + \cot B + \cot C = \dfrac{a^2+b^2+c^2}{4S}$

ស្រាយថា $10^n + 18n - 1$ ចែកដាច់នឹង 27

គ្រប់ $n$ ជាចំនួនគត់ធម្មជាតិ

ចំពោះ $n \geq 1$ : យើងបាន:

$10^n - 1 + 18n$

$(10-1)(10^{n-1}+10^{n-2}+\dots+10+1)+18n$

$9(10^{n-1}+10^{n-2}+\dots+10+1+2n)$

$9(10^{n-1}+10^{n-2}+\dots+10+1-n+3n)$

$9[(10^{n-1}-1)+(10^{n-2}-1)+\dots+(10-1)+(1-1)+3n]$

ដោយ $10^k - 1$ ចែកដាច់នឹង 3

$3n$ ចែកដាច់នឹង 3

ដូចនេះ : $10^n + 18n - 1$ ចែកដាច់នឹង 27

VI (10) ក)




គណនាមុំ $\widehat{PCQ}$

តាមសម្មតិកម្ម : $AQ + AP + PQ = 2$ (1)

និង $AQ + QD = 1$

$AP + PB = 1$

---

$AQ + QD + AP + PB = 2$ (2)

(1) និង (2): $PQ = PB + QD$

លើ (PQ) យកចំនុច M ដែល

$MP = PB$ ; $DQ = QM$

លើបន្លាយ [DA] យកចំនុច E ដែល

$DE = PB$

កាលណា: $\Delta PBC \cong \Delta CDE$

នាំអោយ $CP = CE$

ដូចនេះ: $\Delta CPQ \cong \Delta CQE$ (ករណីទី3

ទាញបាន $\widehat{CQD} = \widehat{CQM}$

នាំអោយ $\Delta CMQ$ កែងត្រង់ M

យើងបាន $\Delta CDQ \cong \Delta CMQ$,

$\Delta CMP \cong \Delta CPB$

នាំអោយ $\widehat{QCD} = \widehat{QCM}$ ; $\widehat{MCP} = \widehat{PCB}$

ឬ $\widehat{PCQ} = \dfrac{\widehat{C}}{2} = 45^\circ$

$\boxed{\widehat{PCQ} = 45^\circ}$

សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

ម) (ស្រាយបញ្ជាក់ថា) $S \le 1$

(20)




តាង ABCD ជាចតុកោណប៉ោងមួយ

ដែល $AB = a$ ; $BC = b$ ; $CD = d$

$AD = d$ យើងបាន

$$S_{ABCD} = S_{ABC} + S_{ACD}$$

$$S = \frac{1}{2} ab \sin \hat{B} + \frac{1}{2} cd \sin \hat{D}$$

$$2S \le ab + cd \quad (1)$$

ដូចគ្នា $S_{ABCD} = S_{ABD} + S_{BCD}$

$$S = \frac{1}{2} ad \sin \hat{A} + \frac{1}{2} bc \sin \hat{C}$$

$$2S \le ad + bc \quad (2)$$

$(1)+(2)$ : $4S \le (ab+cd) + (ad+bc)$

$$\le a(b+d) + c(b+d)$$

$$4S \le (a+c)(b+d)$$

តាម Cauchy : 2 ចំនួន $(a+c)$ និង $(b+d)$

$$4S \le (a+c)(b+d) \le \left(\frac{a+c+b+d}{2}\right)^2$$

$$\le 4$$

$$\boxed{S \le 1}$$ ($p = 2$)

www.pisethsok.wordpress.com

ហ៊ត ស៊ីកាត

# ប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានីភ្នំពេញ

## ថ្ងៃទី ០១ - ៤ - ២០០៣

## វិញ្ញាសាទី២: គណិតវិទ្យាថ្នាក់ទី១២ រយៈពេល ៣ម៉ោង

10P I រកគ្រប់បណ្តាឫស ជាចំនួនពិត នៃសមីការ $\sqrt{x+2002\sqrt{x+2002\sqrt{x+\ldots+2002\sqrt{x+2002\sqrt{2003x}}}}}=x$

( n រ៉ាឌីកាល់ )

10P II គេអោយ $S = 1.2.3+2.3.4+3.4.5+\ldots+n(n+1)(n+2)$

ស្រាយបញ្ជាក់ថា $4S+1$ ជាការេប្រាកដចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។

15P III គេអោយ $n$ ជាចំនួនគត់សេស វិជ្ជមាន និង $n \geq 3$ ។ ស្រាយបញ្ជាក់ថាចំពោះ គ្រប់ចំនួនពិត $x \neq 0$

គេបានជានិច្ច $(1+x+\frac{x^2}{2!}+\frac{x^3}{3!}+\ldots+\frac{x^n}{n!})(1-x+\frac{x^2}{2!}-\frac{x^3}{3!}+\ldots-\frac{x^n}{n!}) < 1$

30P IV ក) គេអោយចតុកោណប៉ោង ABCD ។ អង្កត់ទ្រូងទាំងពីរនៃចតុកោណកាត់គ្នាត្រង់ P ។ ចំងាយពីចំនុច A, B, P ទៅបន្ទាត់ (CD) រៀងគ្នាស្មើ $a, b, p$ ហើយ $CD = c$ ។ ស្រាយបញ្ជាក់ថា $S_{ABCD} = \frac{1}{2p}abc$

ខ) តាមចំនុចមួយនៅក្នុងត្រីកោណ គូសបន្ទាត់ 3 ស្របជាមួយជ្រុងនៃត្រីកោណ ។ បន្ទាត់ទាំងនេះចែកត្រីកោណជា 6 ចំនែក ក្នុងនោះ មាន 3 ចំនែកជាត្រីកោណ ដោយក្រលាផ្ទៃ $S_1$, $S_2$, $S_3$ ។ គណនាក្រលាផ្ទៃត្រីកោណដែលអោយជាអនុគមន៍នៃ $S_1$, $S_2$, $S_3$ ។

15P V គេអោយស្វ៊ីត $(U_n)$ ផ្ទៀងផ្ទាត់ $\begin{cases} U_0 = \frac{\sqrt{2}}{2} \\ U_{n+1} = \frac{\sqrt{2}}{2}\sqrt{1-\sqrt{1-U_n^2}} \quad ; n \geq 0 \end{cases}$

កំនត់កន្សោមនៃ $U_n$ ជាអនុគមន៍នៃ $n$ ។

10P VI. ដោះស្រាយសមីការខាងក្រោម

ក) $(\cos 72^\circ)^x + (\cos 36^\circ)^x = 3 \cdot 2^{-x}$

ខ) $4^{x^2+x} + 2^{1-x^2} = 2^{(x+1)^2} + 1$

10P VII ស្រាយបញ្ជាក់ថា $\underbrace{\sqrt{6+\sqrt{6+\sqrt{6+\ldots+\sqrt{6+\sqrt{6}}}}}}_{n \text{ រ៉ាឌីកាល់}} + \underbrace{\sqrt[3]{30+\sqrt[3]{30+\sqrt[3]{30+\ldots+\sqrt[3]{30+\sqrt[3]{30}}}}}}_{n \text{ រ៉ាឌីកាល់}} < 9$

សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

## កំណែវិញ្ញាសាទី២

**ការគ្រប់គ្រងដំណោះស្រាយប្រព័ន្ធសមីការ**

ល.ខ. $x \geq 0$

តាង $y_1^2 = 2003x = x + 2002x$ (1)

$y_2^2 = x + 2002y_1$ (2)

$y_3^2 = x + 2002y_2$ (3)

- - -

$y_n^2 = x + 2002y_{n-1}$ (n)

នោះគេបាន: គ្រប់ $y_k \geq 0$ $(k = \overline{1,n})$

ដើម្បីការពិនិត្យការបានតាង $y_n = x$

យើងនឹងស្រាយថា $y_1 = x$

ឧបមាថា $x > y_1$

យក (1) − (2): $2002(x - y_1) > 0$

នោះ: $y_1 > y_2$ ដែលផ្ទុយនឹងសម្មតិកម្ម

ដូចគ្នា (2) និង (3); - - -

គេបាន: $y_2 > y_3 > \dots > y_n$

ដូចនេះ: $x > y_1$ នោះ $x > y_n$

ផ្ទុយពីសម្មតិកម្ម $y_n = x$.

ស្រដៀង. បើ $x < y_1$ នោះ $x < y_n$

ផ្ទុយពីសម្មតិកម្ម $y_n = x$.

តាមរយៈ $y_1^2 = 2003x$, $y_1 = x$ នោះ: $2003x = x^2$

$$\boxed{x = 0 \text{ ឬ } x = 2003}$$

(10)

II. $S = 1.2.3 + 2.3.4 + \dots + n(n+1)(n+2)$

ពិនិត្យ: $k(k+1)(k+2)$

$= \frac{1}{4}k(k+1)(k+2)[(k+3) - (k-1)]$

$= \frac{1}{4}k(k+1)(k+2)(k+3) - \frac{1}{4}(k-1)k(k+1)(k+2)$

បើ $k = 1$ : $1.2.3 = \frac{1}{4}1.2.3.4 - 0$

$k = 2$ : $2.3.4 = \frac{1}{4}2.3.4.5 - \frac{1}{4}1.2.3.4$

$k = 3$ : $3.4.5 = \frac{1}{4}3.4.5.6 - \frac{1}{4}2.3.4.5$

⋮

$k = n$ : $n(n+1)(n+2) = \frac{1}{4}n(n+1)(n+2)(n+3) - \frac{1}{4}(n-1)n(n+1)(n+2)$

---

បូកអង្គ: $S = \frac{1}{4}n(n+1)(n+2)(n+3)$

នោះ $4S + 1 = n(n+1)(n+2)(n+3) + 1$

$= (n^2+3n)(n^2+3n+2) + 1$

$= [(n^2+3n)^2 + 2(n^2+3n) + 1]$

$$\boxed{4S + 1 = [n^2 + 3n + 1]^2}$$

VII (15) ស្រាយបញ្ជាក់ថា គ្រប់ចំនួនពិត $x \neq 0$

$n$ ចំនួនគត់សេសវិជ្ជមាន $n \geq 3$

នោះ: $\left(1 + x + \frac{x^2}{2!} + \dots + \frac{x^n}{n!}\right)\left(1 - x + \frac{x^2}{2!} - \dots - \frac{x^n}{n!}\right)$

តាង $F(x) = f(x).g(x)$

យើងនឹងស្រាយថា $F(x) < 1$ គ្រប់ $x \in \mathbb{R}^*$

យក $f(x) = 1 + x + \frac{x^2}{2!} + \dots + \frac{x^n}{n!}$

$f'(x) = 1 + x + \dots + \frac{x^{n-1}}{(n-1)!}$

$f'(x) = f(x) - \frac{x^n}{n!}$

សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

ឃើញ $g(x) = 1 - x + \frac{x^2}{2!} - \frac{x^3}{3!} + \cdots - \frac{x^n}{n!}$

$g'(x) = -1 + x - \frac{x^2}{2!} + \cdots - \frac{x^{n-1}}{(n-1)!}$

$= -\left(1 - x + \frac{x^2}{2!} - \cdots - \frac{x^n}{n!}\right) - \frac{x^n}{n!}$

$= -g(x) - \frac{x^n}{n!}$

ដោយ: $F(x) = f(x)\cdot g(x)$

$F'(x) = f'(x)\cdot g(x) + f(x)\cdot g'(x)$

$= \left[f(x) - \frac{x^n}{n!}\right]g(x) + f(x)\left[-g(x) - \frac{x^n}{n!}\right]$

$= -\frac{x^n}{n!}g(x) - \frac{x^n}{n!}f(x)$

$= -\frac{x^n}{n!}\left[g(x) + f(x)\right]$

$= -\frac{x^n}{n!}2\left(1 + \frac{x^2}{2!} + \frac{x^4}{4!} + \cdots + \frac{x^{n-1}}{(n-1)!}\right)$

($n$ គត់សេស, $n > 3$)

$F'(x)$ មានសញ្ញាដូច $-\frac{x^n}{n!}$

| $x$ | $-\infty$ | $0$ | $+\infty$ |
|---|---|---|---|
| $F'(x)$ | + | 0 | − |
| $F(x)$ | ↗ | 1 | ↘ |

ដូចនេះ $F(x) < 1$ គ្រប់ $x \neq 0$

ក.
(15)




(ស្រាយបញ្ជាក់ថា) $S_{ABCD} = \frac{1}{2p}abc$

តាង $S_{APB} = S_1$, $S_{BPC} = S_2$, $S_{CDP} = S_3$ និង $S_{APD} = S_4$ តាមលក្ខណៈយើងបាន:

$\frac{S_{APD}}{S_{CDP}} = \frac{S_3 + S_4}{S_3} = \frac{a}{p}$

$S_{BCD} = S_2 + S_3 = \frac{1}{2}bc$

គុណអង្គនឹងអង្គ: $\frac{(S_3+S_4)(S_2+S_3)}{S_3} = \frac{1}{2p}ab$

$\left(1 + \frac{S_4}{S_3}\right)(S_2+S_3) = \frac{1}{2p}abc$

$S_2 + S_3 + S_4 + \frac{S_2S_4}{S_3} = \frac{1}{2p}ab$

យើងនឹងស្រាយថា $\frac{S_2S_4}{S_3} = S_1$

គឺស្រាយថា: $\frac{S_4}{S_3} = \frac{S_1}{S_2}$

មាន $\frac{S_1}{S_2} = \frac{AP}{PC}$ (1)

$\frac{S_4}{S_3} = \frac{AP}{PC}$ (2)

(1) និង (2) គេបាន $\frac{S_1}{S_2} = \frac{S_4}{S_3}$

ឬ $S_1 = \frac{S_2S_4}{S_3}$

(*) $S_2 + S_3 + S_4 + S_1 = \frac{1}{2p}abc$

ដូចនេះ: $S = \frac{1}{2p}abc$

ខ)
(15)




www.pisethsok.wordpress.com

ដោយ F ជាចំនុចក្នុង Δ ABC ដែលគូស បន្ទាត់ (DE) // (BC), (PG) // (CA) (MN) // (AB) ដោយ D, G ∈ [AB] M, E ∈ [AC] ; N, P ∈ [BC] ។ រួមមានត្រីកោណ : Δ ABC ; Δ FNP Δ MEF និង Δ DGF គឺ $S; S_1; S_2; S_3$ ហើយត្រីកោណទាំង 4 ដូចគ្នា ។

យើងបាន: $\frac{S_1}{S} = \left(\frac{NP}{BC}\right)^2$

ឬ $\frac{\sqrt{S_1}}{\sqrt{S}} = \frac{NP}{BC}$

ដូចគ្នា: $\frac{\sqrt{S_2}}{\sqrt{S}} = \frac{EF}{BC} = \frac{PC}{BC}$

$\frac{\sqrt{S_3}}{\sqrt{S}} = \frac{DF}{BC} = \frac{BN}{BC}$

បូកអង្គ : $\frac{\sqrt{S_1}+\sqrt{S_2}+\sqrt{S_3}}{\sqrt{S}} = \frac{NP+PC+BN}{BC} = \frac{BC}{BC} = 1$

នាំឱ្យបាន $\sqrt{S} = \sqrt{S_1}+\sqrt{S_2}+\sqrt{S_3}$

$$S = \left(\sqrt{S_1}+\sqrt{S_2}+\sqrt{S_3}\right)^2$$

ស្វ៊ីត $(u_n)$ កំណត់ដោយ

$u_0 = \frac{\sqrt{2}}{2}$

$u_{n+1} = \frac{\sqrt{2}}{2}\sqrt{1-\sqrt{1-u_n^2}}$ ; $n \geq 0$

កំណត់តួទូទៅ $u_n$ ជាអនុគមន៍នៃ n

គេ $u_0 = \frac{\sqrt{2}}{2} = \sin\frac{\pi}{2^2}$

$u_1 = \frac{\sqrt{2}}{2}\sqrt{1-\sqrt{1-u_0^2}}$

$u_1 = \frac{\sqrt{2}}{2}\sqrt{1-\sqrt{1-\sin^2\frac{\pi}{2^2}}}$

$= \frac{\sqrt{2}}{2}\sqrt{1-\sqrt{\cos^2\frac{\pi}{2^2}}}$

$= \frac{\sqrt{2}}{2}\sqrt{1-\cos\frac{\pi}{2^2}}$

$= \frac{\sqrt{2}}{2}\sqrt{2\sin^2\frac{\pi}{2^3}} = \sin\frac{\pi}{2^3}$

ឧបមា $u_k = \sin\frac{\pi}{2^{k+2}}$ (10)

នាំឱ្យ $u_{k+1} = \frac{\sqrt{2}}{2}\sqrt{1-\sqrt{1-\sin^2\frac{\pi}{2^{k+2}}}}$

$= \frac{\sqrt{2}}{2}\sqrt{1-\cos\frac{\pi}{2^{k+2}}}$

$= \frac{\sqrt{2}}{2}\sqrt{2\sin^2\frac{\pi}{2^{k+3}}}$

$= \sin\frac{\pi}{2^{k+3}}$ ពិត (5)

តាមវិចារកំណើនគេបាន: $u_n = \sin\frac{\pi}{2^{n+2}}$

VI ដោះស្រាយសមីការ :

(5) ក) $(\cos72°)^x + (\cos36°)^x = 3\cdot2^{-x}$

គុណនឹង $2^x$ : $(2\cos72°)^x + (2\cos36°)^x = 3$ (1)

គេមាន : $2\cos72°\cdot2\cos36°$

$= \frac{2\sin36°\cos36°\cdot2\cos72°}{\sin36°}$

$= \frac{\sin72°\cdot2\cos72°}{\sin36°} = \frac{\sin144°}{\sin36°}$

$= \frac{\sin(180°-36°)}{\sin36°} = \frac{\sin36°}{\sin36°} = 1$

ហេតុនេះ: $(2\cos72°)^x\cdot(2\cos36°)^x = 1$ (2)

តាម (1) និង (2) , ប៉ុន្តែចំនួនទាំងពីរ $(2\cos72°)^x$ និង $(2\cos36°)^x$ ជាឫសសមីការ

$$t^2 - 3t + 1 = 0 \quad (3)$$

សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

សមីការ (3) មានឫស $t_1 = \frac{3-\sqrt{5}}{2}$

$t_2 = \frac{3+\sqrt{5}}{2}$

គេស្គាល់ថា: $2\cos 72^\circ = 2\sin 18^\circ = \frac{\sqrt{5}-1}{2}$

គេបាន $\left(\frac{\sqrt{5}-1}{2}\right)^x = \frac{3-\sqrt{5}}{2} = \left(\frac{\sqrt{5}-1}{2}\right)^2$

$x = 2$

$\left(\frac{\sqrt{5}-1}{2}\right)^x = \frac{3+\sqrt{5}}{2} = \left(\frac{\sqrt{5}-1}{2}\right)^{-2}$

$x = -2$

ដូចនេះ: សមីការមានឫសពីរ $x = 2$, $x = -2$

ខ) $4^{x^2+x} + 2^{1-x^2} = 2^{(x+1)^2} + 1$

$2^{2(x^2+x)} + 2^{1-x^2} - 2^{(x+1)^2} - 1 = 0$

$2^{2(x^2+x)} + 2^{1-x^2} - 2^{2(x^2+x)} \cdot 2^{1-x^2} - 1 = 0$

$2^{2(x^2+x)}\left(1 - 2^{1-x^2}\right) - \left(1 - 2^{1-x^2}\right) = 0$

$\left(1 - 2^{1-x^2}\right)\left(2^{2(x^2+x)} - 1\right) = 0$

$1 - 2^{1-x^2} = 0$ នាំ: $1 - x^2 = 0$

$x = \pm 1$

$2^{2(x^2+x)} - 1 = 0$

$2(x^2+x) = 0$ ឬ $x = 0$

$x = -1$

ដូចនេះ: សមីការមានឫសបីគឺ:

$x = 0;\ x = -1;\ x = 1$

10) VII ស្រាយបញ្ជាក់ថា:

$\sqrt{6+\sqrt{6+\cdots\sqrt{6}}} + \sqrt{30+\sqrt{30+\cdots+\sqrt{30}}}$

មាន

$\sqrt{6+\sqrt{6+\cdots+\sqrt{6}}} < \sqrt{6+\sqrt{6+\cdots+\sqrt{9}}} < 3$

$\sqrt{30+\sqrt{30+\cdots+\sqrt{30}}} < \sqrt{30+\sqrt{30+\cdots+\sqrt{36}}} < 6$

ដូចនេះ:

$\sqrt{6+\sqrt{6+\cdots+\sqrt{6}}} + \sqrt{30+\sqrt{30+\cdots+\sqrt{30}}} < 9$

www.pisethsok.wordpress.com
សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

(6)

ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា រូបវិទ្យា

ថ្នាក់ទី ៩ និងទី ១២ ឆ្នាំសិក្សា ២០០៣-២០០៤

សម័យប្រឡង: ១១-៥-០៤

វិញ្ញាសា គណិតវិទ្យា ថ្នាក់ទី ១២ លើកទី១ ថ្ងៃទី ១១-៥-០៤ (រយៈពេល ៣ ម៉ោង)

អធិការ គណិតវិទ្យា
TEL: 011 953 029

១-(ពិន្ទុ១០) គេចែកការេមួយដែលមានជ្រុងប្រវែង 3 ឯកតា ជា ៩ ក្រឡាប៉ុនៗគ្នា។
ចូរយកចំនួនគត់ពី 1 ដល់ 9 ទៅបំពេញក្នុងក្រឡាទាំង ៩ នោះដើម្បីអោយបានផលបូកចំនួនតាមជួរដេកនីមួយៗស្មើ 15 ផលបូកចំនួនតាមជួរឈរនីមួយៗស្មើ 15 ហើយផលបូកចំនួនតាមអង្កត់ទ្រូងនីមួយៗស្មើ 15 ដែលក្រឡានីមួយៗមានចំនួនគត់តែមួយគត់ហើយខុសៗគ្នា។

២-(ពិន្ទុ១០) កំនត់រិសធំបំផុតនៃសមីការ $x^{2004}+3x^{2002}-10x^{2000}=4x^{2003}-8x^{2001}$ នៅក្នុងសំនុំចំនួនពិត។

៣-(ពិន្ទុ១០) បង្ហាញថា $1^n+8^n-3^n-6^n$ ចែកដាច់នឹង 10 ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ។

៤-(ពិន្ទុ១០) n ជាចំនួនគត់វិជ្ជមាន។ $(u_n)$ ជាស្វ៊ីតនព្វន្ត ហើយ $(v_n)$ ជាស្វ៊ីតធរណីមាត្រ ដែលផ្ទៀងផ្ទាត់ :

$$u_{m+1}=v_{m+1}=a$$
$$u_{n+1}=v_{n+1}=b$$
$$u_{p+1}=v_{p+1}=c \quad \text{ដែល } a>0\,;\,b>0\,;\,c>0 \text{ ។}$$

បង្ហាញថា $(a^{b-c})(b^{c-a})(c^{a-b})=1$ ។

៥-(ពិន្ទុ១៥) បង្ហាញថា គ្មានចំនួនគត់ x ; y ; z ណាដែលផ្ទៀងផ្ទាត់សមីការ $x^2+y^2-8z=6$ ទេ។

៦-(ពិន្ទុ២០) អនុគមន៍ f កំនត់ដោយ $y=f(x)=\sqrt[3]{\dfrac{x^3-3x+(x^2-1)\sqrt{x^2-4}}{2}}+\sqrt[3]{\dfrac{x^3-3x-(x^2-1)\sqrt{x^2-4}}{2}}$

គណនាតំលៃនៃ $f(\sqrt[4]{2004})$ ។

៧-(ពិន្ទុ២៥) M ជាចំនុចមួយស្ថិតនៅលើជ្រុង[AC]នៃត្រីកោណABC មួយដែលមានផ្ទៃក្រលា $a^2$ ។

$r_1$ និង $r_2$ ជាកាំរៀងគ្នានៃរង្វង់ចារឹកក្នុងត្រីកោណ ABM និងBCM ។

ក្នុងករណីដែល $r_1=r_2$ បង្ហាញថា $BM^2=a^2\cot\left(\dfrac{B}{2}\right)$ ។

(Bជារង្វាស់មុំក្នុងនៃត្រីកោណ ABC ត្រង់កំពូល B)



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

អត្រាកំរែគណិតវិទ្យា

វិញ្ញាសាទី១ សំរាប់ថ្ងៃទី ១១-៤-០៤

១-(ពិន្ទុ១០)

| | | |
|---|---|---|
| 4 | 9 | 2 |
| 3 | 5 | 7 |
| 8 | 1 | 6 |

| | | |
|---|---|---|
| 2 | 7 | 6 |
| 9 | 5 | 1 |
| 4 | 3 | 8 |

២-(ពិន្ទុ១០) កំនត់ឫសធំបំផុតនៃសមីការ :

គេបាន : $x^{2000}\left(x^4-4x^3+3x^2+8x-10\right)=0$ ពិន្ទុ2

$x^{2000}\left(x^4-4-4x^3+8x+3x^2-6\right)=0$

$x^{2000}\left[(x^2-2)(x^2+2)-4x(x^2-2)+3(x^2-2)\right]=0$ ពិន្ទុ4

$x^{2000}(x^2-2)(x^2-4x+5)=0$

$x^{2000}=0$ នោះ $x=0$

$x^2-2=0$ នោះ $x=\pm\sqrt{2}$

$x^2-4x+5=0$ មាន $\Delta'=-1$ ពិន្ទុ4

សមីការមានឫសធំបំផុត $x=\sqrt{2}$

៣-(ពិន្ទុ១០) បង្ហាញថា $1^n+8^n-3^n-6^n$ ចែកដាច់នឹង 10 :

តាង $S=1^n+8^n-3^n-6^n$

គេបាន $S=(1-3)(1+3+\cdots+3^{n-1})+(8-6)(8^{n-1}+8^{n-2}\cdot 6+\cdots+6^{n-1})$

$S=(-2)(1+3+\cdots+3^{n-1})+(2)(8^{n-1}+8^{n-2}\cdot 6+\cdots+6^{n-1})$

$S=2p\ ;p=-1-3-\cdots-3^{n-1}+8^{n-1}+8^{n-2}\cdot 6+\cdots+6^{n-1}$ ពិន្ទុ4

ដូចនេះ S ចែកដាច់នឹង 2 (1)

ម្យ៉ាងទៀត :

$S=(1^n-6^n)+(8^n-3^n)$

$S=(1-6)(1+6+\cdots+6^{n-1})+(8-3)(8^{n-1}+8^{n-2}\cdot 3+\cdots+3^{n-1})$

$S=(-5)(1+6+\cdots+6^{n-1})+(5)(8^{n-1}+8^{n-2}\cdot 3+\cdots+3^{n-1})$

$S=5q\ ;q=-1-6-\cdots-6^{n-1}+8^{n-1}+8^{n-2}\cdot 3+\cdots+3^{n-1}$ ពិន្ទុ3

ដូចនេះ S ចែកដាច់នឹង 5 (2)

តាម (1) និង (2) គេបាន $1^n+8^n-3^n-6^n$ ចែកដាច់នឹង 10 ពិន្ទុ3



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

៤-(ពិន្ទុ១០) បង្ហាញថា $(a^{b-c})(b^{c-a})(c^{a-b}) = 1$

គេមាន:

$a = u_1 + md = v_1 q^m$

$b = u_1 + nd = v_1 q^n$

$c = u_1 + pd = v_1 + q^p$ ពិន្ទុ3

$b - c = d(n-p)\ ;\ c - a = d(p-m)\ ;\ a - b = d(m-n)$

គេបាន : $(a^{b-c})(b^{c-a})(c^{a-b}) = (v_1 q^m)^{d(n-p)}(v_1 q^n)^{d(p-m)}(v_1 q^p)^{d(m-n)}$

$= (v_1^{d(n-p+p-m+m-n)})(q^{d(mn-mp+np-nm+mp-np)})$

$= (v_1^0)(q^0) = 1$

ដូចនេះ $\boxed{(a^{b-c})(b^{c-a})(c^{a-b}) = 1}$ ពិន្ទុ7

៥-(ពិន្ទុ១៥) បង្ហាញថាគ្មានចំនួនគត់ $x, y, z$ ដែលផ្ទៀងផ្ទាត់ $x^2 + y^2 - 8z = 6$ ទេ :

ចំពោះគ្រប់ចំនួនគត់ $n$ គេបាន :

$n = 4a + r$ ដែល $a$ ជាចំនួនគត់ និង $r = 0;1;2;3$

$n^2 = 8(2a^2 + r) + r^2 = 8b + r^2$ ដែល $b = 2a^2 + r$ ជាចំនួនគត់ហើយ $r^2 = 0;1;4;9$

នេះបញ្ជាក់ថា $n^2 = 8m + s$ ដែល $m$ ជាចំនួនគត់ និង $s = 0;1;4$ ពិន្ទុ5

ចំពោះគ្រប់ចំនួនគត់ $x\ ;\ y$ គេបាន :

$x^2 = 8p + s$ ដែល $p$ ជាចំនួនគត់ និង $s = 0;1;4$

$y^2 = 8q + t$ ដែល $q$ ជាចំនួនគត់ និង $t = 0;1;4$

$x^2 + y^2 = 8(p+q) + (s+t) = 8z + v$ ដែល $z = p + q$ ជាចំនួនគត់ និង $v = 0;1;2;4;5$ ពិន្ទុ5

បានន័យថា ចំពោះគ្រប់ចំនួនគត់ $x;y;z$ គេបាន :

$x^2 + y^2 - 8z = 0$

ឬ $x^2 + y^2 - 8z = 1$

ឬ $x^2 + y^2 - 8z = 2$

ឬ $x^2 + y^2 - 8z = 4$

ឬ $x^2 + y^2 - 8z = 5$

ដូចនេះ | គ្មានចំនួនគត់ $x, y, z$ ដែលផ្ទៀងផ្ទាត់ $x^2 + y^2 - 8z = 6$ ទេ | ពិន្ទុ5

៦-(ពិន្ទុ២០) គណនា $f(\sqrt[3]{2004})$ :

តាង $A = \sqrt[3]{\dfrac{x^3 - 3x + (x^2-1)\sqrt{x^2-4}}{2}}$ និង $B = \sqrt[3]{\dfrac{x^3 - 3x - (x^2-1)\sqrt{x^2-4}}{2}}$

គេបាន : $A^3 + B^3 = x^3 - 3x$ ពិន្ទុ5

www.pisethsok.wordpress.com



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

តាង $A + B = y$

$$A \cdot B = \sqrt[3]{\frac{(x^3-3x)^2-(x^2-1)^2(x^2-4)}{4}} = \sqrt[3]{\frac{4}{4}} = 1$$

$y^3 = (A+B)^3$

$= A^3 + B^3 + 3AB(A+B)$

$y^3 = x^3 - 3x + 3y$

$y^3 - x^3 + 3x - 3y = 0$ ពិន្ទុ10

$(y-x)(y^2+xy+x^2-3) = 0$

$y - x = 0$ គេបាន $y = x$

$y^2 + xy + x^2 - 3 = 0$ មាន $\Delta = -3x^2 + 12 < 0$ ព្រោះ $x = \sqrt[4]{2004}$ → ធំជាង និង 3

គេបាន $y = x = \sqrt[4]{2004}$

ដូចនេះ $\boxed{f(\sqrt[4]{2004}) = \sqrt[4]{2004}}$ ពិន្ទុ5

ឝ-(ពិន្ទុ២៥) បង្ហាញថា $BM^2 = a^2 \cot\left(\frac{B}{2}\right)$ :




ពិន្ទុ5

តាង : $s_1$ និង $p_1$ ជាផ្ទៃក្រលា និង កន្លះបរិមាត្រនៃត្រីកោណ ABM

$s_2$ និង $p_2$ ជាផ្ទៃក្រលា និង កន្លះបរិមាត្រនៃត្រីកោណ MBC

$s$ និង $p$ ជាផ្ទៃក្រលា និង កន្លះបរិមាត្រនៃត្រីកោណ ABC

$r$ ជាកាំរង្វង់ចារឹកក្នុង $\Delta ABC$

$I$ និង $I'$ ជាចំនុចប៉ះរវាង$[AB]$ជាមួយរង្វង់ចារឹកក្នុង$\Delta ABC$ និង$\Delta ABM$

$J$ និង $J'$ ជាចំនុចប៉ះរវាង$[BC]$ជាមួយរង្វង់ចារឹកក្នុង$\Delta ABC$ និង$\Delta MBC$



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

គេបាន :

$s = pr$

$s_1 = p_1r_1$

$s_2 = p_2r_2$

$s = s_1 + s_2 = p_1r_1 + p_2r_2$

$pr = p_1r' + p_2r' = (p_1 + p_2)r'$ (1) ព្រោះ $r_1 = r_2 = r'$ ពិន្ទុ

ម្យ៉ាងទៀត : $2p_1 + 2p_2 = 2p + 2BM$ រឺ $p_1 + p_2 = p + BM$

(1) អាចសរសេរ : $pr = (p + BM)r'$ ហើយ $\frac{r'}{r} = \frac{p}{p+BM}$ (2)

$\Delta I'AO_1 \sim \Delta IAO$ : $\frac{AI'}{AI} = \frac{r'}{r}$ ហើយ $\Delta J'CO_2 \sim \Delta JCO$ : $\frac{CJ'}{CJ} = \frac{r'}{r}$ (3) ពិន្ទុ

ក្នុងត្រីកោណABC គេមាន $p = AI + BJ + JC = AI + BC$

នោះ $AI = p - BC$

ក្នុងត្រីកោណABC គេមាន $p = CJ + AI + IB = CJ + AB$

នោះ $CJ = p - AB$

តាមរបៀបដូចគ្នា :

ក្នុងត្រីកោណABM គេមាន $AI' = p_1 - BM$

ក្នុងត្រីកោណMBC គេមាន $CJ' = p_2 - BM$

(3) : $\frac{r'}{r} = \frac{p_1 - BM}{p - BC} = \frac{p_2 - BM}{p - AB} = \frac{p_1 + p_2 - 2BM}{2p - (BC + AB)}$

$\frac{r'}{r} = \frac{p + BM - 2BM}{AC}$ ព្រោះ $p_1 + p_2 = p + BM$ ហើយ $2p = AC + BC + AB$

$\frac{r'}{r} = \frac{p - BM}{AC}$ (4) ពិន្ទុ

តាម (2) និង (4) :

$\frac{p}{p+BM} = \frac{p - BM}{AC}$ នាំអោយ $p \cdot AC = p^2 - BM^2$

នាំអោយ $BM^2 = p(p - AC) = p \cdot BI$ (5) ព្រោះ $BI = p - AC$

ក្នុងត្រីកោណកែងIBO : $BI = r\cot \hat{OBI} = r\cot\left(\frac{B}{2}\right)$

(5) : $MB^2 = (pr)\cot\left(\frac{B}{2}\right) = a^2\cot\left(\frac{B}{2}\right)$ ព្រោះ $a^2 = pr$

ដូចនេះ

$$\boxed{BM^2 = a^2\cot\left(\frac{B}{2}\right)}$$

ពិន្ទុ



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា រូបវិទ្យា

ថ្នាក់ទី ៩ និងទី ១២ ឆ្នាំសិក្សា ២០០៣-២០០៤

សម័យប្រឡង: ១១-៥-០៤

វិញ្ញាសា គណិតវិទ្យា ថ្នាក់ទី ១២ លើកទី២ ថ្ងៃទី ១៣-៥-០៤ (រយៈពេល ៣ ម៉ោង)

១-(ពិន្ទុ១០) នារី សុខ និង សៅ ជាបេក្ខជនសិស្សពូកែថ្នាក់ទី១២លើមុខវិជ្ជាផ្សេង១គ្នា (គណិតវិទ្យា រូបវិទ្យា និង ភាសាខ្មែរ)។

(1): បើនារី ប្រលងគណិតវិទ្យា នោះ សុខ ប្រលងរូបវិទ្យា។

(2): បើនារី ប្រលងភាសាខ្មែរ នោះ សៅ ប្រលងរូបវិទ្យា។

(3): បើ សុខ មិនប្រលងភាសាខ្មែរ នោះ សៅ ប្រលងគណិតវិទ្យា ។

តើបេក្ខជនណាប្រលងមុខវិជ្ជាណា ?

២-(ពិន្ទុ១៥)ចូរបំពេញលេខអោយបានសមស្របត្រង់សញ្ញា * ក្នុងការគណនាផលគុណរវាងពីរចំនួន ដែលនៅខាងស្តាំនេះដោយបកស្រាយពន្យល់ផង។

```
       * * *
     × * 2 *
     -------
       * * *
   * * * *
   * 8 *
  ---------
 * * 9 * 2 *
```

៣-(ពិន្ទុ១៥) $(x_n)$ ជាស្វ៊ីតនៃចំនួនដែលកំនត់ដោយ: $x_1 = 2003, x_2 = 2004$ និង $x_{n+1} = x_n(x_n - 1) + 2$ ចំពោះ $n \geq 2$

បង្ហាញថា $(x_1^2+1)(x_2^2+1)\dots(x_{2004}^2+1) - 1 = (x_{2005} - 1)^2$ ។

៤-(ពិន្ទុ១៥) $a, b, c, d$ ជាបួនចំនួនគត់ដែលចែកមិនដាច់នឹង 5 ។

$m$ ជាចំនួនគត់មួយដែលធ្វើអោយ $am^3 + bm^2 + cm + d$ ចែកដាច់នឹង 5 ។

បង្ហាញថា មានចំនួនគត់ $n$ ដែលធ្វើអោយ $dn^3 + cn^2 + bn + a$ ចែកដាច់នឹង 5 ដែរ ។

៥-(ពិន្ទុ២០) $a_1, a_2, \dots, a_n$ និង $b_1, b_2, \dots, b_n$ ជាចំនួនពិត ។

ក-បង្ហាញថា $(a_1b_1 + a_2b_2 + \cdots + a_nb_n)^2 \leq (a_1^2 + a_2^2 + \cdots + a_n^2)(b_1^2 + b_2^2 + \cdots + b_n^2)$

បញ្ជាក់ថាវិសមភាពខាងលើក្លាយជាសមភាពកាលណា $\frac{a_1}{b_1} = \frac{a_2}{b_2} = \cdots = \frac{a_n}{b_n}$ ។

ខ-ដោះស្រាយប្រព័ន្ធសមីការដែលមានអញ្ញាត $x_1, x_2, \dots, x_{2004}$ :

$$\begin{cases} \sqrt{1+x_1} + \sqrt{1+x_2} + \cdots + \sqrt{1+x_{2004}} = 2004\sqrt{\frac{2005}{2004}} & (1) \\ \sqrt{1-x_1} + \sqrt{1-x_2} + \cdots + \sqrt{1-x_{2004}} = 2004\sqrt{\frac{2003}{2004}} & (2) \end{cases}$$

៦-(ពិន្ទុ២៥) រង្វង់ពីរមានកាំ $R$ និង $r$ $(R > r)$ មានផ្ចិតរួម $O$ ហើយស្ថិតក្នុងប្លង់តែមួយ។ $M$ ជាចំនុចនឹងនៅលើរង្វង់តូច ហើយ $B$ ជាចំនុចចល័តលើរង្វង់ធំ។ បន្ទាត់ $(BM)$ ជួបរង្វង់ធំម្តងទៀតត្រង់ចំនុច $C$ ។ បន្ទាត់ $(L)$ កែងនឹង $(BM)$ ត្រង់ $M$ ។ បន្ទាត់ $(L)$ ជួបរង្វង់តូច ម្តងទៀតត្រង់ $A$ ។

ក-គណនា ផលបូក $S = BC^2 + CA^2 + AB^2$ ជាអនុគមន៍នៃ $R$ និង $r$ ។

ខ-យក $I$ ជាចំនុចកណ្តាលនៃ $[AB]$ ។ កំនត់សំណុំនៃចំនុច $I$ ។



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

# ទិញ្ញសាទិ២ សំរាប់ថ្ងៃទី ១៣.៤.០៤

១-(ពិន្ទុ១០) -បើ នារី ប្រលង គណិតវិទ្យា នោះ សុខ ប្រលង រូបវិទ្យា ( តាម(1) )

តាម(3) គេបាន សៅ ប្រលង គណិតវិទ្យា ព្រោះសុខមិនប្រលងភាសាខ្មែរ ។ (1p)

គេបាន នារី និង សៅ ប្រលង គណិតវិទ្យាតែមួយ ដែលជាករណីមិនអាចមាន ។ + (2p)

ដូចនេះ នារីមិនប្រលងគណិតវិទ្យាទេ ។ = ពិន្ទុ3

-បើនារីប្រលងភាសាខ្មែរ នោះ សៅប្រលងរូបវិទ្យា (តាម(2)) ។

ក្នុងករណីនេះ សុខត្រូវប្រលងគណិតវិទ្យា (គឺមិនប្រលងភាសាខ្មែរទេ) ហើយបណ្តាលអោយសៅប្រលង 1p

គណិតវិទ្យាដែរ (តាម(3)) ។ គេបាន សុខ និង សៅ ប្រលង គណិតវិទ្យាតែមួយ ដែលជាករណីមិនអាចមាន ។ 2p

ដូចនេះ នារីមិនប្រលងភាសាខ្មែរទេ គឺ នារីច្បាស់ជាប្រលង រូបវិទ្យា ។ = ពិន្ទុ3

-បើសុខមិនប្រលងភាសាខ្មែរ គឺសុខប្រលងគណិតវិទ្យា (ព្រោះសល់តែខ្មែរនិងគណិត) ។ 1p

តែតាម(3) គេបាន សៅ ប្រលងគណិតវិទ្យាដែរ ជាករណីមិនអាចមាន ។ដូចនេះ សុខប្រលងភាសាខ្មែរ ។ 1p

សរុបមកគេបាន :

| នារីប្រលង រូបវិទ្យា សុខប្រលងភាសាខ្មែរ ហើយ សៅប្រលង គណិតវិទ្យា |
|---|

2p = ពិន្ទុ4

២-(ពិន្ទុ១៥)

-ដោយ $2\times***$ នៃតំនាងគុណ បានចំនួនដែលមានលេខបួនខ្ទង់ ហើយ(*) ទៅតួគុណ គុណនឹង * * *

ទៅតំនាងគុណ បានចំនួនដែលមានលេខបីខ្ទង់ នោះ(*) = 1 ។ គេបានតួគុណ = 121 ។ {2, 1, 2} = ពិន្ទុ5

-ដោយ 1 ទៅខ្ទង់រយនៃតួគុណ គុណនឹង(*) ទៅខ្ទង់ដប់នៃតំនាងគុណ បានលទ្ធផល 8 នោះ (*) = 8 ។ ពិន្ទុ2

-ដោយផលគុណមានលេខខ្ទង់ដប់ស្មើ 2 នោះ(*) ទៅខ្ទង់ឯកតា នៃតំនាងគុណត្រូវស្មើ 7 ។ ពិន្ទុ2

-ដោយ 2 គុណនឹង (*) ទៅខ្ទង់រយនៃតំនាងគុណ បានចំនួនមានលេខពីរខ្ទង់ ហើយខ្ទង់ឯកតាត្រូវបូកនឹង 8 ផង បូកនឹងលេខដែលត្រាទុកផងដើម្បីអោយបាន 9 នោះ(*) = 9 (គេសាកចាប់ពី 5 ដល់ 9) ។ ពិន្ទុ2

ដូចនេះគេបាន :

$$
\begin{array}{r}
987 \\
\times\ 121 \\
\hline
987 \\
1974\phantom{0} \\
987\phantom{00} \\
\hline
119427
\end{array}
$$

ពិន្ទុ4



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

៣-(ពិន្ទុ១៥) បង្ហាញថា $(x_1^2+1)(x_2^2+1)\cdots(x_{2004}^2+1)-1=(x_{2005}-1)^2$

តាង $S_n=(x_1^2+1)(x_2^2+1)\cdots(x_n^2+1)-1$

គេនឹងបង្ហាញថា $S_n=(x_{n+1}-1)^2$ ពិន្ទុ2

-ចំពោះ $n=1$ គេបាន $S_1=(x_1^2+1)-1=(2003)^2=(2004-1)^2=(x_2-1)^2$ : ពិត

-ឧបមាថាទំនាក់ទំនងពិតដល់ $n=p$ : $S_p=(x_{p+1}-1)^2$ ពិន្ទុ3

-ពិនិត្យចំពោះ $n=p+1$ :

$S_{p+1}=(x_1^2+1)(x_2^2+1)\cdots(x_{p+1}^2+1)-1=\left[(x_1^2+1)(x_2^2+1)\cdots(x_p^2+1)-1+1\right](x_{p+1}^2+1)-1$ ពិន្ទុ2

$=\left[S_p+1\right](x_{p+1}^2+1)-1=\left[(x_{p+1}-1)^2+1\right](x_{p+1}^2+1)-1$

$=\left[(x_{p+1}^2+1)-2x_{p+1}+1\right](x_{p+1}^2+1)-1$ ពិន្ទុ2

$=\left[(x_{p+1}^2+1)^2-2x_{p+1}(x_{p+1}^2+1)+(x_{p+1}^2+1)\right]-1$

$=\left[(x_{p+1}^2+1)-x_{p+1}\right]^2=\left[x_{p+1}(x_{p+1}-1)+2-1\right]^2=(x_{p+2}-1)^2$

$S_{p+1}=(x_{p+2}-1)^2$ : ទំនាក់ទំនងពិតចំពោះ $n=p+1$ ពិន្ទុ4

ដូចនេះ $S_n=(x_{n+1}-1)^2$ ចំពោះគ្រប់ $n$ ; $n\geq 1$ ។

ដោយយក $n=2004$ គេបាន $\boxed{(x_1^2+1)(x_2^2+1)\cdots(x_{2004}^2+1)-1=(x_{2005}-1)^2}$ ពិន្ទុ2

៤-(ពិន្ទុ១៥) បង្ហាញថាមានចំនួនគត់ $n: dn^3+cn^2+bn+a$ ចែកដាច់នឹង 5 :

តាង : $A=am^3+bm^2+cm+d$

$B=dn^3+cn^2+bn+a$

A ចែកដាច់នឹង 5 តែ d ចែកមិនដាច់នឹង 5 នោះ $am^3+bm^2+cm$ ចែកមិនដាច់នឹង 5 (2p)

ដោយ $am^3+bm^2+cm=m(am^2+bm+c)$ ចែកមិនដាច់នឹង 5 នោះគេបាន m ចែកមិនដាច់នឹង 5 ។

គេបាន $m=5q+r$ ដែល q ជាចំនួនគត់ ហើយ $r=1;2;3;4$ ។ (2p) = ពិន្ទុ4

គេសិក្សា $An^3-B=am^3n^3+bm^2n^3+cmn^3-cn^2-bn-a$ (2p)

$=a(m^3n^3-1)+bn(m^2n^2-1)+cn^2(mn-1)$

$=(mn-1)(am^2n^2+amn+a+bmn^2+bn+cn^2)$

$B=An^3-(mn-1)(am^2n^2+amn+a+bmn^2+bn+cn^2)$ (2p) = ពិន្ទុ4

ដើម្បីអោយ B ចែកដាច់នឹង 5 គេគ្រាន់តែជ្រើសរើសចំនួនគត់ n ដែលធ្វើអោយ $mn-1$ ចែកដាច់នឹង 5 ។

បើ $m=5q+r$ ; $n=5p+s$ នោះគេបាន $mn-1=5k+rs-1$ ដែល $k=5pq+qs+pr$ (2p)

ដើម្បីអោយ $mn-1$ ចែកដាច់នឹង 5 លុះត្រាតែ $rs-1$ ចែកដាច់នឹង 5 ។ (1p) = ពិន្ទុ3

ដោយ $1\leq r\leq 4$ នោះគេអាចរក s បាន តាមរបៀបដូចខាងក្រោម :

បើ $r=1$ នោះ $s=1$ ; $n=5p+1$ ដែល p ជាចំនួនគត់ (1p)

បើ $r=2$ នោះ $s=3$ ; $n=5p+3$ ដែល p ជាចំនួនគត់ (1p)



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

បើ $r = 3$ នោះ $s = 2$ ; $n = 5p + 2$ ដែល $p$ ជាចំនួនគត់ (1p)

បើ $r = 4$ នោះ $s = 4$ ; $n = 5p + 4$ ដែល $p$ ជាចំនួនគត់ (1p)

ដូចនេះ **គេអាចរកបាន n ដែលធ្វើអោយ B ចែកដាច់នឹង 5** = ពិន្ទុ4

៥-(ពិន្ទុ២០) ក-បង្ហាញថា $(a_1b_1 + a_2b_2 + \cdots + a_nb_n)^2 \le (a_1^2 + a_2^2 + \cdots + a_n^2)(b_1^2 + b_2^2 + \cdots + b_n^2)$

-បើ $a_1 = a_2 = \cdots = a_n = 0$ នោះគេបាន $0 \le 0$ : ពិត (1p)

-បើមាន $a_i \ne 0$ នោះ $a_1^2 + a_2^2 + \cdots + a_n^2 > 0$ ហើយគេមាន :

$(a_1x + b_1)^2 = a_1^2x^2 + 2a_1b_1x + b_1^2 \ge 0$ , $\forall x \in \mathbb{R}$

$(a_2x + b_2)^2 = a_2^2x^2 + 2a_2b_2x + b_2^2 \ge 0$ , $\forall x \in \mathbb{R}$

---

$(a_nx + b_n)^2 = a_n^2x^2 + 2a_nb_nx + b_n^2 \ge 0$ , $\forall x \in \mathbb{R}$ (2p) = ពិន្ទុ3

បូកអង្គនិងអង្គ :

$(a_1^2 + a_2^2 + \cdots + a_n^2)x^2 + 2(a_1b_1 + a_2b_2 + \cdots + a_nb_n)x + (b_1^2 + b_2^2 + \cdots + b_n^2) \ge 0$ , $\forall x \in \mathbb{R}$ (2)

លុះត្រាតែ :

$\Delta' = (a_1b_1 + a_2b_2 + \cdots + a_nb_n)^2 - (a_1^2 + a_2^2 + \cdots + a_n^2)(b_1^2 + b_2^2 + \cdots + b_n^2) \le 0$ (3)

ដូចនេះ $\boxed{(a_1b_1 + a_2b_2 + \cdots + a_nb_n)^2 \le (a_1^2 + a_2^2 + \cdots + a_n^2)(b_1^2 + b_2^2 + \cdots + b_n^2)}$ = ពិន្ទុ5

-កាលណា $\dfrac{a_1}{b_1} = \dfrac{a_2}{b_2} = \cdots = \dfrac{a_n}{b_n} = t$ គេបាន :

$(a_1b_1 + a_2b_2 + \cdots + a_nb_n)^2 = t^2(b_1^2 + b_2^2 + \cdots + b_n^2)^2$ (i) (1p)

$(a_1^2 + a_2^2 + \cdots + a_n^2)(b_1^2 + b_2^2 + \cdots + b_n^2) = t^2(b_1^2 + b_2^2 + \cdots + b_n^2)^2$ (ii) (1p)

តាម(i)និង(ii) :

$\boxed{(a_1b_1 + a_2b_2 + \cdots + a_nb_n)^2 = (a_1^2 + a_2^2 + \cdots + a_n^2)(b_1^2 + b_2^2 + \cdots + b_n^2)}$ = ពិន្ទុ2

ខ-ដោះស្រាយប្រព័ន្ធសមីការ :

ដែនកំណត់ : $-1 \le x_i \le 1$ , $i = 1, 2, \ldots, 2004$

(1) សមមូល $(\sqrt{1+x_1} + \sqrt{1+x_2} + \cdots + \sqrt{1+x_{2004}})^2 = (2004)(2005)$ (1p)

$(\sqrt{1+x_1} + \sqrt{1+x_2} + \cdots + \sqrt{1+x_{2004}})^2 \le (1 + 1 + \cdots + 1)(1 + x_1 + 1 + x_2 + \cdots + 1 + x_{2004})$ (1p)

$(\sqrt{1+x_1} + \sqrt{1+x_2} + \cdots + \sqrt{1+x_{2004}})^2 \le (2004)(2004 + x_1 + x_2 + \cdots + x_{2004})$

$(2004)(2005) \le (2004)(2004 + x_1 + x_2 + \cdots + x_{2004})$

$1 \le x_1 + x_2 + \cdots + x_{2004}$ (3) (1p) = ពិន្ទុ3

(2) សមមូល $(\sqrt{1-x_1} + \sqrt{1-x_2} + \cdots + \sqrt{1-x_{2004}})^2 = (2004)(2003)$ (1p)

$(\sqrt{1-x_1} + \sqrt{1-x_2} + \cdots + \sqrt{1-x_{2004}})^2 \le (2004)(2004 - x_1 - x_2 - \cdots - x_{2004})$



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

$(2004)(2003) \le (2004)(2004 - x_1 - x_2 - \cdots - x_{2004})$ (1p)

$x_1 + x_2 + \cdots + x_{2004} \le 1$ (4) (1p) = ៦ពិន្ទុ

តាម (3) និង (4) : $x_1 + x_2 + \cdots + x_{2004} = 1$ (5) (1p)

វិសមភាពក្លាយជាសមភាព នោះគេបាន : $\sqrt{1+x_1} = \sqrt{1+x_2} = \cdots = \sqrt{1+x_{2004}}$ (1p)

ហើយ $x_1 = x_2 = \cdots = x_{2004}$ (1p)

(5) អាចសរសេរ : $2004x_1 = 1$ ហើយ $x_1 = \dfrac{1}{2004}$ (1p)

ដូចនេះ

$$\boxed{x_1 = x_2 = \cdots = x_{2004} = \frac{1}{2004}}$$

= ៤ពិន្ទុ

៦-(ពិន្ទុ២៥)ក -គណនាផលបូក S :




ត្រូវតាមលម្អិតបម=៥ពិន្ទុ

តាម : [MM'] ជាអង្កត់ផ្ចិតរង្វង់តូច ។ $\widehat{OMA} = \alpha$ ហើយ N ជាចំនុចកណ្ដាលនៃ [BC] ។ (2p)

គេបាន $S = BC^2 + CA^2 + AB^2 = (BM + MC)^2 + (MC^2 + MA^2) + (MB^2 + MA^2)$ (1p)

$S = 2(MA^2 + MB^2 + MC^2 + MB \cdot MC)$ (1) = ពិន្ទុ3

-ក្នុងត្រីកោណកែង AMM' : $MA = 2r\cos\alpha$ (1p)

$= (x_{p-2} - q_p x_{p-1})a + (y_{p-2} - q_p y_{p-1})b$

$r_p = x_p a + y_p b$ ដែល $x_p = x_{p-2} - q_p x_{p-1}$ ; $y_p = y_{p-2} - q_p y_{p-1} \in Z$ ៣ពិន្ទុ

បានន័យថា ទំនាក់ទំនងពិតចំពោះគ្រប់ p ដែល $1 \le p \le n$

យក $p = n$ គេបាន $r_n = x_n a + y_n b$ ដែល $x_n , y_n \in Z$

ដូចនេះ $\boxed{\text{មាន } u = x_n ,\ v = y_n \in Z \text{ ដែល } d = au + bv}$ ២ពិន្ទុ

www.pisethsok.wordpress.com
សុខ ពិសិដ្ឋ
គ្រូបង្រៀនគណិតវិទ្យា

ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា រូបវិទ្យា

សម័យប្រឡង: ០១.០៤.២០០៩

វិញ្ញាសា: គណិតវិទ្យា ថ្នាក់ទី ១២ លើកទី១ ថ្ងៃទី ០១.០៤.០៩ (រយៈពេល ១៨០ នាទី ពិន្ទុ ១០០)

១. (១០ពិន្ទុ) គេឲ្យរង្វង់បីដែលកាត់គ្នាតាមរូបខាងក្រោម ។ សង់រូបឡើងវិញហើយបង្ហាញថាចំណុច E ; D និង F នៅលើបន្ទាត់តែមួយ ។




២. (១០ពិន្ទុ) បង្ហាញថា $1^{2009}+2^{2009}+3^{2009}+\cdots+(n-1)^{2009}+n^{2009}$ ចែកមិនដាច់នឹង $n+2$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។

៣. (១៥ពិន្ទុ) គេមាន $f(x)=x^2-3x+3$ ។

ក. បង្ហាញថា បើ $f(x)=x$ នោះ $f(f(x))=x$ ។

ខ. រកឫសនៃសមីការ $f(x)=x$ ។ ទាញរកឫសនៃសមីការ $(x^2-3x+3)^2-3(x^2-3x+3)+3=x$ ។

៤. (១៥ពិន្ទុ) គេតាង $n!=n(n-1)(n-2)\times\cdots\times 2\times 1$ ។ បង្ហាញថា ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ គេបាន :

$$1+\frac{2009}{1!}+\frac{(2009)(2010)}{2!}+\cdots+\frac{(2009)(2010)\cdots(2009+n-1)}{n!}=\frac{(2010)(2011)\cdots(2009+n)}{n!}$$

៥. (១៥ពិន្ទុ) អនុគមន៍ $g$ កំណត់ចំពោះគ្រប់ចំនួនពិត $x$ ដោយ $g(x+1)+g(x-1)=\sqrt{2}\,g(x)$ ។

ក. គេតាង $g(x)=p$ និង $g(x-1)=q$ ចំពោះគ្រប់ចំនួនពិត $x$ ។

គណនា $g(x+1), g(x+2), g(x+3)$ និង $g(x+4)$ ជាអនុគមន៍នៃ $p$ និង $q$ ។

ខ. បង្ហាញថា $g$ ជាអនុគមន៍ខួប ។

៦. (១៥ពិន្ទុ) គេឲ្យស្វ៊ីតនៃចំនួនពិត $(u_n)$ ដែលកំណត់ដោយ $u_1=\frac{1}{2}$ និង $u_n=\left(\frac{2n-3}{2n}\right)u_{n-1}$ ចំពោះ $n=2;3;\cdots$ ។

បង្ហាញថា $u_1+u_2+\cdots+u_n<1$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។

៧. (២០ពិន្ទុ) ត្រីកោណកែង $ABC$ មួយមានអ៊ីប៉ូតេនុស $BC=a$ និងកម្ពស់ $AH=h$ ។ គេចែក $[BC]$ ជា $n$ ចំណែកស្មើៗគ្នា ដែល $n$ ជាចំនួនគត់សេស ។ គេយក $[PQ]$ ជាចំណែកដែលនៅកណ្តាលគេ ហើយដែលរង្វាស់មុំ $P\hat{A}Q=x$ ។

បង្ហាញថា $\tan x=\frac{4nh}{a(n^2-1)}$ ។

សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

## អត្រាកំណែគណិតវិទ្យា ថ្នាក់ទី១២

## សម្រាប់ថ្ងៃទី ០១_០៤_២០០៩

១. (១០ពិន្ទុ) បង្ហាញថាចំណុច E; D និង F នៅលើបន្ទាត់តែមួយ :




៣ពិន្ទុ

គេមាន

$E\hat{D}B = M\hat{A}B$ ២ពិន្ទុ

$M\hat{A}B = B\hat{C}F$

គេបាន $E\hat{D}B = B\hat{C}F$ ២ពិន្ទុ

តែ $B\hat{C}F + B\hat{D}F = 180^0$ នោះ $E\hat{D}B + B\hat{D}F = 180^0$ ៣ពិន្ទុ

ដូចនេះ ចំណុច E; D និង F នៅលើបន្ទាត់តែមួយ ។

២. (១០ពិន្ទុ) បង្ហាញថា $1^{2009} + 2^{2009} + 3^{2009} + \cdots + (n-1)^{2009} + n^{2009}$ ចែកមិនដាច់នឹង $n+2$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ :

គេមាន

$S_n = 1^{2009} + 2^{2009} + 3^{2009} + \cdots + (n-1)^{2009} + n^{2009}$

$2S_n = (n^{2009} + 2^{2009}) + ((n-1)^{2009} + 3^{2009}) + \cdots + (2^{2009} + n^{2009}) + 1^{2009} + 1^{2009}$ ២ពិន្ទុ

$= (n+2)k_1 + (n+2)k_2 + \cdots + (n+2)k_{n-1} + 2$ ៣ពិន្ទុ

$= (n+2)k + 2$ ដែល $k = k_1 + k_2 + \cdots + k_{n-1}$ ជាចំនួនគត់វិជ្ជមាន

គេទាញបាន $2S_n$ ចែកមិនដាច់នឹង $n+2$ ៣ពិន្ទុ

ដូចនេះ $S_n$ ចែកមិនដាច់នឹង $n+2$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។ ២ពិន្ទុ

៣. (១៧ពិន្ទុ) គេមាន $f(x) = x^2 - 3x + 3$ ។

ក. បង្ហាញថា បើ $f(x) = x$ នោះ $f(f(x)) = x$ :

បើ $f(x) = x$ នោះ $f(f(x)) = f(x)$

ដូចនេះ $f(f(x)) = x$ ព្រោះ $f(x) = x$ ៣ពិន្ទុ

ខ. រកឫសនៃសមីការ $f(x) = x$ :

សមីការ $f(x) = x$ អាចសរសេរជា $x^2 - 4x + 3 = 0$ ដែលមានឫស $x_1 = 1$ ; $x_2 = 3$ ៣ពិន្ទុ

ទាញ រកឫសនៃសមីការ $(x^2 - 3x + 3)^2 - 3(x^2 - 3x + 3) + 3 = x$ :

សមីការ $(x^2 - 3x + 3)^2 - 3(x^2 - 3x + 3) + 3 = x$ អាចសរសេរជា

$f(f(x)) = x$ ដែលជាសមីការផលវិបាកនៃ $f(x) = x$ ៣ពិន្ទុ

គេទាញបាន $x_1 = 1$ ; $x_2 = 3$ ជាឫសនៃ $(x^2 - 3x + 3)^2 - 3(x^2 - 3x + 3) + 3 = x$

ពី $x_1 = 1$ ; $x_2 = 3$ ជាឫសនៃ $x^4 - 6x^3 + 12x^2 - 10x + 3 = 0$ ៣ពិន្ទុ

$(x^2 - 4x + 3)(x-1)^2 = 0$

សមីការមានឫស $x_1 = 1$ ; $x_2 = 3$ ៣ពិន្ទុ

សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

(១៥ពិន្ទុ) បង្ហាញថា ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n គេបាន :

$$1+\frac{2009}{1!}+\frac{(2009)(2010)}{2!}+\cdots+\frac{(2009)(2010)\cdots(2009+n-1)}{n!}=\frac{(2010)(2011)\cdots(2009+n)}{n!}$$

- ចំពោះ $n=1$ : $1+\frac{2009}{1}=\frac{2010}{1}$ ជាសមភាពដែលពិត ៣ពិន្ទុ

- ឧបមាថា សមភាពពិតដល់ $n=k$ មានន័យថា :

$$1+\frac{2009}{1!}+\frac{(2009)(2010)}{2!}+\cdots+\frac{(2009)(2010)\cdots(2009+k-1)}{k!}=\frac{(2010)(2011)\cdots(2009+k)}{k!}$$ ៣ពិន្ទុ

- ពិនិត្យចំពោះ $n=k+1$

$$1+\frac{2009}{1!}+\frac{(2009)(2010)}{2!}+\cdots+\frac{(2009)(2010)\cdots(2009+k-1)}{k!}+\frac{(2009)(2010)\cdots(2009+k)}{(k+1)!}=$$

$$=\frac{(2010)(2011)\cdots(2009+k)}{k!}+\frac{(2009)(2010)\cdots(2009+k)}{(k+1)!}$$ ៣ពិន្ទុ

$$=\frac{(2010)(2011)\cdots(2009+k)(k+1)}{(k+1)!}+\frac{(2009)(2010)\cdots(2009+k)}{(k+1)!}$$ ៣ពិន្ទុ

$$=\frac{(2010)(2011)\cdots(2009+k)(2009+(k+1))}{(k+1)!}$$ ពិតចំពោះ $n=k+1$ ៣ពិន្ទុ

៥. (១៥ពិន្ទុ) ក. គណនា $g(x+1); g(x+2); g(x+3); g(x+4)$:

គេមាន $g(x+1)=\sqrt{2}\,g(x)-g(x-1)$

ដោយ $g(x-1)=q$ ; $g(x)=p$ ចំពោះគ្រប់ $x\in R$ នោះគេបាន ១ពិន្ទុ

$g(x+1)=\sqrt{2}\,p-q$

$g(x+2)=\sqrt{2}\,g(x+1)-g(x)=\sqrt{2}(\sqrt{2}\,p-q)-p=p-\sqrt{2}\,q$ ចំពោះគ្រប់ $x\in R$ ២ពិន្ទុ

$g(x+3)=\sqrt{2}\,g(x+2)-g(x+1)=\sqrt{2}(p-\sqrt{2}\,q)-\sqrt{2}p+q=-q$ ចំពោះគ្រប់ $x\in R$ ២ពិន្ទុ

$g(x+4)=\sqrt{2}\,g(x+3)-g(x+2)=\sqrt{2}(-q)-p+\sqrt{2}\,q=-p=-g(x)$ ចំពោះគ្រប់ $x\in R$ ២ពិន្ទុ

ខ. បង្ហាញថា g ជាអនុគមន៍ខួប :

$g(x+5)=\sqrt{2}\,g(x+4)-g(x+3)=-\sqrt{2}\,p+q$ ចំពោះគ្រប់ $x\in R$ ២ពិន្ទុ

$g(x+6)=\sqrt{2}\,g(x+5)-g(x+4)=\sqrt{2}(-\sqrt{2}\,p+q)-(-p)=\sqrt{2}\,q-p$ ចំពោះគ្រប់ $x\in R$ ២ពិន្ទុ

$g(x+7)=\sqrt{2}\,g(x+6)-g(x+5)=\sqrt{2}(\sqrt{2}\,q-p)-(-\sqrt{2}p+q)=q$ ចំពោះគ្រប់ $x\in R$ ២ពិន្ទុ

$g(x+8)=\sqrt{2}\,g(x+7)-g(x+6)=\sqrt{2}\,q-(\sqrt{2}\,q-p)=p=g(x)$ ចំពោះគ្រប់ $x\in R$ ១ពិន្ទុ

ដូចនេះ g ជាអនុគមន៍ខួប ។

របៀបទី២ : តាមសំណួរខាងលើ $g(x+4)=-g(x)$ នោះគេអាចសរសេរ : ៤ពិន្ទុ

$g(x+8)=g((x+4)+4)=$

$g(x+8)=-g(x+4)=-(-g(x))=g(x)$ ចំពោះគ្រប់ $x\in R$ ៤ពិន្ទុ

ដូចនេះ g ជាអនុគមន៍ខួប ។

៦. (១៥ពិន្ទុ) បង្ហាញថា $u_1+u_2+\cdots+u_n<1$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ។ ៣ពិន្ទុ

- ចំពោះ $k\geq 2$ គេបាន $2ku_k=2ku_{k-1}-3u_{k-1}$ ហើយ $u_{k-1}=2(k-1)u_{k-1}-2ku_k$



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

ដោយប្តូរតម្លៃ $k=2;\cdots;n-1$

$u_1 = 2u_1 - 4u_2$

$u_2 = 4u_2 - 6u_3$ ៣ពិន្ទុ

$\dots\dots\dots\dots\dots\dots$

$u_{n-1} = 2(n-1)u_{n-1} - 2nu_n$ ៣ពិន្ទុ

$u_n = 2nu_n - 2(n+1)u_{n+1}$

---

$$\sum_{i=1}^{n} u_i = 2u_1 - (2n+2)u_{n+1} = 1-(2n+2)u_{n+1}$$ ៣ពិន្ទុ

ដោយ $u_n > 0$ ចំពោះគ្រប់ $n$ នោះ $u_1+u_2+\cdots+u_n<1$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។ ៣ពិន្ទុ

ឃ. (២០ពិន្ទុ) បង្ហាញថា $\tan x = \dfrac{4nh}{a(n^2-1)}$ :




៣ពិន្ទុ

តាង M ជាចំណុចកណ្ដាលនៃ$[BC]$ ។

យើងមាន $x = \hat{PAQ} = \hat{PAH} - \hat{QAH}$ ២ពិន្ទុ

$\tan x = \tan\left(\hat{PAH} - \hat{QAH}\right)$

$$= \frac{\tan\hat{PAH} - \tan\hat{QAH}}{1+\tan\hat{PAH}\times\tan\hat{QAH}}$$ ៣ពិន្ទុ

ដែល $\tan\hat{PAH} = \dfrac{HP}{HA}$ ; $\tan\hat{QAH} = \dfrac{HQ}{HA}$

$$\tan x = \frac{(HP-HQ)\times HA}{HA^2+HP\times HQ} = \frac{PQ\times HA}{HA^2+HP\times HQ} \quad (1)$$ ៣ពិន្ទុ

ដោយ $HP = HM + MP = HM + \dfrac{a}{2n}$ និង $HQ = HM - MQ = HM - \dfrac{a}{2n}$ ៣ពិន្ទុ

$$HM^2 = AM^2 - AH^2 = \frac{a^2-4h^2}{4}$$

$$HP\times HQ = HM^2 - \frac{a^2}{4n^2} = \frac{a^2-4h^2}{4} - \frac{a^2}{4n^2} = \frac{a^2n^2-4n^2h^2-a^2}{4n^2}$$ ៣ពិន្ទុ

$$\tan x = \frac{ah}{n}\times\frac{4n^2}{4n^2h^2+a^2n^2-4n^2h^2-a^2} = \frac{4nh}{a(n^2-1)}$$ ៣ពិន្ទុ

ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៩

ប្រធានក្រុមកំណែ គណិតវិទ្យា ថ្នាក់ទី ១២

អ៊ី សៀងលី



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

# ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

## ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា រូបវិទ្យា

## សម័យប្រឡង: ០១.០៤.២០០៩

វិញ្ញាសា គណិតវិទ្យា ថ្នាក់ទី ១២ លើកទី២ ថ្ងៃទី ០៣.០៤.០៩ (រយៈពេល ១៨០ នាទី ពិន្ទុ ១០០)

១. (១០ពិន្ទុ) គេឲ្យចំណុច M មួយនៃកន្លះរង្វង់ដែលមានអង្កត់ផ្ចិត [AB] ។

រកសំណុំចំណុចនៃចំណុច M កាលណា A ចល័តលើផ្នែក [Ox) និង B ចល័តលើ ផ្នែក [Oy) នៃមុំកែង xOy មួយដោយរក្សាប្រវែង AB ថេរ ។




២. (១០ពិន្ទុ) បង្ហាញថា $3^{2n} + 2^{6n-5}$ ចែកដាច់នឹង 11 ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ។

៣. (១៥ពិន្ទុ) គេឲ្យចំនួនគត់វិជ្ជមាន a និង b ដែល $2a^2 + a = 3b^2 + b$ ។

បង្ហាញថា $a - b$ ; $2a + 2b + 1$ និង $3a + 3b + 1$ សុទ្ធតែជាការេប្រាកដ ។

៤. (១៥ពិន្ទុ) សំណុំ $E_n$ មួយមាន n ធាតុដែល n ជាចំនួនគត់វិជ្ជមាន ។ តាង $P(E_n)$ ជាសំណុំនៃសំណុំរងរបស់ $E_n$ ហើយ

$\text{Card}\left(P(E_n)\right)$ ជាចំនួនធាតុនៃ $P(E_n)$ ។ តាមវិចារដោយកំណើន បង្ហាញថា $\text{Card}\left(P(E_n)\right) = 2^n$ ។

៥. (១៥ពិន្ទុ) ត្រីកោណ ABC មួយមានជ្រុង $BC = a$ ; $AC = b$ ដែល $a + b = (a\tan A + b\tan B)\tan\frac{C}{2}$ ។

បង្ហាញថា ABC ជាត្រីកោណសមបាត ។

៦. (១៥ពិន្ទុ) ស្វ៊ីត $(x_n)$ មួយកំណត់ដោយ $x_1 = 1$ និង $x_{n+1} = 1 + x_1 x_2 \cdots x_n$ ចំពោះ $n = 1, 2, \cdots$ ។

គេតាងផលបូក $S_n = \sum_{k=1}^{n} \frac{1}{x_k}$ ។

គណនា $\lim_{n \to +\infty} S_n$ ។

៧. (២០ពិន្ទុ) អនុគមន៍ $f(x;y)$ មួយផ្ទៀងផ្ទាត់លក្ខខណ្ឌទាំងបីខាងក្រោមចំពោះគ្រប់ចំនួនគត់មិនអវិជ្ជមាន x និង y :

(i) $f(0;y) = 1 + y$

(ii) $f(x+1;0) = f(x;1)$

(iii) $f(x+1;y+1) = f\left(x; f(x+1;y)\right)$ ។

ក. គណនា $f(1;n)$, $f(2;n)$ និង $f(3;n)$ ជាអនុគមន៍នៃ n ។

ខ. គណនា $f(4;2009)$ ។

www.pisethsok.wordpress.com

សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

# អត្រាកំណែ គណិតវិទ្យា ថ្នាក់ទី ១២

## សម្រាប់ថ្ងៃទី ០៣_០៤_០៩

១. (១០ពិន្ទុ) រកសំណុំចំណុចនៃចំណុច M :




២ពិន្ទុ ចតុកោណ AMBO ចារឹកក្នុងរង្វង់មួយ ។

គេតាង $\hat{MAB} = \alpha$ ថេរ $AB = 2R$ ថេរ

គេបាន $\hat{MOB} = \hat{MAB} = \alpha$ ថេរ ២ពិន្ទុ

បានន័យថា M នៅលើ $[OM)$ ដែល $\hat{MOy} = \alpha$ ២ពិន្ទុ

លីមីត: - បើ $A = O$ នោះ $B = B_1$ ដែល $OB_1 = 2R$ ហើយ $M = M_1$ ដែល $OM_1 = 2R\cos\alpha$

- បើ $B = O$ នោះ $A = A_1$ ដែល $OA_1 = 2R$ ហើយ $M = M_2$ ដែល $OM_2 = 2R\sin\alpha$ ២ពិន្ទុ

សន្និដ្ឋាន :

សំណុំចំណុចនៃចំណុច M គឺជា $[M_1M_2]$ នៃ $[OM)$ ដែល $\hat{MOy} = \alpha$ , $OM_1 = 2R\cos\alpha$ និង $OM_2 = 2R\sin\alpha$ ។ ២ពិន្ទុ

២. (១០ពិន្ទុ) បង្ហាញថា $3^{2n} + 2^{6n-5}$ ចែកដាច់នឹង 11 ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n :

ចំពោះ $n = 1$ គេបាន $3^2 + 2^{6\times1-5} = 11$ ចែកដាច់នឹង 11 : ពិត ២ពិន្ទុ

ឧបមាថាពិតដល់ $n = k$ គឺថា $3^{2k} + 2^{6k-5} = 11p$ , $p \in Z^+$ ៣ពិន្ទុ

នាំឱ្យ $3^{2k} = 11p - 2^{6k-5}$ , $p \in Z^+$

ពិនិត្យចំពោះ $n = k+1$ គេបាន $3^{2(k+1)} + 2^{6(k+1)-5} = 9\times3^{2k} + 2^6\times2^{6k-5}$ ២ពិន្ទុ

$= 9\times11p - 9\times2^{6k-5} + 2^6\times2^{6k-5} = 11(9p + 5\times2^{6k-5})$ ចែកដាច់នឹង 11 : ពិត

ដូចនេះ $3^{2n} + 2^{6n-5}$ ចែកដាច់នឹង 11 ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ។ ៣ពិន្ទុ

៣. (១៥ពិន្ទុ) បង្ហាញថា $a - b$ ; $2a + 2b + 1$ និង $3a + 3b + 1$ សុទ្ធតែជាការេប្រាកដ :

ដោយ $2a^2 + a = 3b^2 + b$ នោះគេបាន :

$a^2 = a - b + 3a^2 - 3b^2 = (a-b)(3a+3b+1)$ ៣ពិន្ទុ

$b^2 = a - b + 2a^2 - 2b^2 = (a-b)(2a+2b+1)$

បើ δ ជាតួចែករួមធំបំផុតនៃ $3(a+b)+1$ & $2(a+b)+1$ នោះ $\delta \mid (6a+6b+3-6a-6b-2)$ គឺ $\delta \mid 1$ ៣ពិន្ទុ

ដូចនេះ $PGCD(3(a+b)+1; 2(a+b)+1) = 1$ ហើយ $PGCD(a^2; b^2) = a - b$

ម្យ៉ាងទៀត គេតាង $d = PGCD(a;b)$ នោះ $a = dp ; b = dq$ ដែល $PGCD(p;q) = 1$ ៣ពិន្ទុ

គេបាន $a^2 = d^2p^2 ; b^2 = d^2q^2$ ៣ពិន្ទុ

ដោយ $PGCD(p^2;q^2) = 1$ នោះ $d^2 = PGCD(a^2;b^2)$

គេទាញបាន $a - b = d^2 ; 3a + 3b + 1 = p^2 ; 2a + 2b + 1 = q^2$ ៣ពិន្ទុ

៤. (១៥ពិន្ទុ) បង្ហាញថា $Card(P(E_n)) = 2^n$ :

- ចំពោះ $n = 1$ : $E_1 = \{a_1\}$ ហើយ $P(E_1) = \{\emptyset, \{a_1\}\}$ នោះគេបាន $Card(P(E_1)) = 2 = 2^1$ ៣ពិន្ទុ

- ឧបមាថាវាសំណើពិតដល់ $n = k$ : គេបាន $E_k = \{a_1, a_2, a_3, \dots, a_k\}$ ហើយ $Card(P(E_k)) = 2^k$ ៣ពិន្ទុ

- ពិនិត្យចំពោះ $n = k+1$ : គេបាន $E_{k+1} = \{a_1, a_2, a_3, \dots, a_k, a_{k+1}\} = E_k \cup \{a_{k+1}\}$ ៣ពិន្ទុ



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

$\lim_{n\to+\infty} 2^{n+1} = +\infty$ នោះ $\lim_{n\to+\infty} (x_{n+1} - 1) = +\infty$ ១ពិន្ទុ

នាំឱ្យ $\lim_{n\to+\infty} \frac{1}{x_{n+1} - 1} = 0$

ដូចនេះ $\lim_{n\to+\infty} S_n = 2$ ២ពិន្ទុ

៧-(២០ពិន្ទុ)

ក. គណនា $f(1;n)$, $f(2;n)$ និង $f(3;n)$ ជាអនុគមន៍នៃ $n$ :

គេបាន $f(1;n) = f(0; f(1;n-1)) = 1 + f(1;n-1)$ ; $n \geq 1$ ១ពិន្ទុ

តាង $p_n = f(1;n)$ គេបាន $p_0 = f(1;0) = f(0;1) = 1+1 = 2$ ; $p_n = p_{n-1} + 1$ ចំពោះ $n \geq 1$

គេបាន $(p_n)$ ជាស្វ៊ីតនព្វន្តដែលមាន $p_0 = 2; d = 1$ ៣ពិន្ទុ

ដូចនេះ $f(1;n) = p_n = p_0 + nd = n + 2$

គេមាន $f(2;n) = f(1; f(2;n-1)) = f(2;n-1) + 2$ ; $n \geq 1$ ១ពិន្ទុ

តាង $q_n = f(2;n)$ គេបាន $q_0 = f(2;0) = f(1;1) = p_1 = 1 + 2 = 3; q_n = q_{n-1} + 2$ ចំពោះ $n \geq 1$

គេបាន $(q_n)$ ជាស្វ៊ីតនព្វន្តដែលមាន $q_0 = 3; d' = 2$

ដូចនេះ $f(2;n) = q_n = q_0 + nd' = 2n + 3$ ២ពិន្ទុ

គេមាន $f(3;n) = f(2; f(3;n-1)) = 2f(3;n-1) + 3$ ចំពោះ $n \geq 1$ ១ពិន្ទុ

$f(3;n) + 3 = 2(f(3;n-1) + 3)$

តាង $u_n = f(3;n) + 3$ នោះគេបាន $u_0 = f(3;0) + 3 = f(2;1) + 3 = (2 \times 1 + 3) + 3 = 8$

ហើយ $u_n = 2(f(3;n-1) + 3) = 2u_{n-1}$ ចំពោះ $n \geq 1$ ២ពិន្ទុ

គេបាន $(u_n)$ ជាស្វ៊ីតធរណីមាត្រដែលមាន $u_0 = 8$ ; $q = 2$ ១ពិន្ទុ

ហើយ $u_n = u_0 q^n = 2^{n+3}$

ដូចនេះ $f(3;n) = 2^{n+3} - 3$ ២ពិន្ទុ

ខ. គណនា $f(4;2009)$

គេមាន $f(4;n) = f(3; f(4;n-1)) = 2^{f(4;n-1)+3} - 3$ , $n \geq 1$ ២ពិន្ទុ

$f(4;0) = f(3;1) = 2^4 - 3 = 2^{2^2} - 3$ មាននិទស្សន្ត 2 ចំនួន $0 + 2$ ដង ១ពិន្ទុ

$f(4;1) = 2^{f(4;0)+3} - 3 = 2^{16} - 3 = 2^{2^{2^2}} - 3$ មាននិទស្សន្ត 2 ចំនួន $1 + 2$ ដង ១ពិន្ទុ

.....................................................................................

$f(4;n) = 2^{2^{\cdot^{\cdot^{2}}}} - 3$ មាននិទស្សន្ត 2 ចំនួន $n + 2$ ដង ២ពិន្ទុ

ដោយយក $n = 2009$ នោះ $f(4;2009) = 2^{2^{\cdot^{\cdot^{2}}}} - 3$ មាននិទស្សន្ត 2 ចំនួន $2009 + 2 = 2011$ ដង ២ពិន្ទុ

ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៩

ប្រធានក្រុមកំរែ គណិតវិទ្យា ថ្នាក់ទី១២

អ៊ី សាវឿន



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

ផ្នែកអក្សរសាស្ត្រខ្មែរ គណិតវិទ្យា រូបវិទ្យា ថ្នាក់ទី ៩ និងថ្នាក់ទី ១២

[illegible]

វិញ្ញាសា: គណិតវិទ្យា ថ្នាក់ទី ១២ លើកទី២ ថ្ងៃទី ០៩.០៤.២០១០

រយៈពេល ១៨០នាទី ពិន្ទុ ១០០

I. (១០ពិន្ទុ) ១. ដោះស្រាយ [illegible] ជាចំនួនគត់ [illegible]

២. បង្ហាញថា [illegible] ចំពោះគ្រប់ចំនួនគត់ [illegible]

II. (១០ពិន្ទុ) [illegible]

III. (១០ពិន្ទុ) ត្រីកោណ XYZ មួយមាន $X = $ [illegible] $, YZ = x, ZX = y$ និង $XY = z$ ។

បង្ហាញថា $x^2 \geq$ [illegible] [illegible]

IV. (១៥ពិន្ទុ) គេបានបេះផ្លែស្វាយមកប្រមូលជា 11 គំនរស្មើៗគ្នា ហើយនៅសល់ផ្លែស្វាយចំនួន 6 ផ្លែទៀត ។ តែបើគេយកផ្លែស្វាយទាំងនោះមកប្រមូលជា 17 គំនរស្មើៗគ្នាវិញ គេនៅតែមានផ្លែស្វាយនៅសល់ ។

រកចំនួនផ្លែស្វាយតិចបំផុតដែលគេបានបេះ ។

V. (២០ពិន្ទុ) ចតុកោណប៉ោង ABCD មួយមានជ្រុង $AB = a ; BC = b ; CD = c ; DA = d$ ។ យកមុំ $\hat{ABC} = x$ និង $\hat{ADC} = y$ ។

រកលក្ខខណ្ឌដើម្បីឲ្យចតុកោណ ABCD ចារឹកក្នុងរង្វង់បាន ។

VI. (២០ពិន្ទុ) ស្វ៊ីតនៃចំនួន $(u_n)$ កំណត់ដោយ $u_1 = 1 ; u_2 = 1$ និង $u_n = u_{n-1} + u_{n-2}$ ចំពោះ $n = 3, 4, \ldots$ ។

តាង $a = \frac{1+\sqrt{5}}{2}$ និង $b = \frac{1-\sqrt{5}}{2}$ ។

១. បង្ហាញថា $u_n \geq a^{n-2}$ ចំពោះគ្រប់ចំនួនគត់ $n \geq 3$ ។

២. បង្ហាញថា $u_n = \frac{1}{\sqrt{5}}(a^n - b^n)$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។

សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

# អត្រាកំណែគណិតវិទ្យា ថ្នាក់ទី ១២

## សម្រាប់ថ្ងៃទី ០១-០៤-២០១០

$k_2$

$x^4+4y^4=(x^4+4x^2y^2+4y^4)-4x^2y^2=(x^2+2y^2+2xy)(x^2+2y^2-2xy)$ ៥ពិន្ទុ

២. បង្ហាញថា $n^4+4^n$ មិនមែនជាចំនួនបឋមទេ ចំពោះគ្រប់ចំនួនគត់រ៉ឺឡាទីប $n>1$ ៖

ចំពោះគ្រប់ចំនួនគត់រ៉ឺឡាទីប $n>1$ គេមានពីរករណី ៖

- បើ $n=2k$ ដែល $k=1,2,\ldots$ គេបាន $n^4+4^n=16(k^4+16^{k-1})$ ដែលមិនមែនជាចំនួនបឋមទេ ។ ៥ពិន្ទុ
- បើ $n=2k+1$ ដែល $k=1,2,\ldots$ គេបាន $n^4+4^n=n^4+4^{2k+1}=n^4+4(2^k)^4$

$=(n^2+2^{2k+1}-n2^{k+1})(n^2+2^{2k+1}+n2^{k+1})$ ដែលមិនមែនជាចំនួនបឋមទេ ។ ៥ពិន្ទុ

II. ១៥ពិន្ទុ) រកអនុគមន៍ $g$ ដែលផ្ទៀងផ្ទាត់សមីការ $g(x)+g\left(\frac{1}{1-x}\right)=x$ ចំពោះគ្រប់ចំនួនពិត $x$ ដែល $x\neq 0, x\neq 1$ ៖

- ជំនួស $x$ ដោយ $\frac{1}{1-x}$ គេបាន $g\left(\frac{1}{1-x}\right)+g\left(1-\frac{1}{x}\right)=\frac{1}{1-x}$ ៥ពិន្ទុ
- ជំនួស $x$ ដោយ $1-\frac{1}{x}$ គេបាន $g\left(1-\frac{1}{x}\right)+g(x)=1-\frac{1}{x}$ ៥ពិន្ទុ

គេបាន $g(x)+g\left(\frac{1}{1-x}\right)=x$ $\quad -g\left(\frac{1}{1-x}\right)-g\left(1-\frac{1}{x}\right)=-\frac{1}{1-x}$ $\quad g\left(1-\frac{1}{x}\right)+g(x)=1-\frac{1}{x}$

ដោយបូកអង្គ និងអង្គ គេបាន $g(x)=\frac{1}{2}\left(x+1-\frac{1}{x}-\frac{1}{1-x}\right)$ ចំពោះ $x\neq 0, x\neq 1$ ។ ៥ពិន្ទុ

III. ១៥ពិន្ទុ) ត្រីកោណកែង $XYZ$ មួយមាន $\hat{X}=90^0$, $YZ=x$, $ZX=y$ និង $XY=z$ ។

បង្ហាញថា $x^n>y^n+z^n$ ចំពោះគ្រប់ចំនួនគត់រ៉ឺឡាទីប $n$ ដែល $n\geq 3$

- ចំពោះ $n=3$

គេមាន $x^2=y^2+z^2 \Rightarrow x^3=xy^2+xz^2$ ៥ពិន្ទុ




តែ $x>y \Rightarrow xy^2>y^3$ ហើយ $x>z \Rightarrow xz^2>z^3$

គេទាញបាន $x^3=xy^2+xz^2>y^3+z^3$

- ឧបមាថា $x^k>y^k+z^k$ ចំពោះ $k\geq 3$ ៥ពិន្ទុ
- ពិនិត្យចំពោះ $k+1$

$x^k>y^k+z^k \Rightarrow x^{k+1}>xy^k+xz^k$

តែ $x>y \Rightarrow xy^k>y^{k+1}$ ហើយ $x>z \Rightarrow xz^k>z^{k+1}$ ៥ពិន្ទុ

គេទាញបាន $x^{k+1}>xy^k+xz^k>y^{k+1}+z^{k+1}$

IV. ១៥ពិន្ទុ) រកចំនួនផ្លែស្វាយតិចបំផុតដែលគេបានបេះ ៖

តាងដោយ $M$ ចំនួនផ្លែស្វាយតិចបំផុតដែលសោភាបានបេះ ។

- ដោយដឹងថា គេបានរៀបគរផ្លែស្វាយជា 11 គំនរស្មើៗគ្នា និងនៅសល់ផ្លែស្វាយចំនួន 6 ផ្លែ នោះគេបាន ៖ ៥ពិន្ទុ

$M\equiv 6 \pmod{11} \Rightarrow M=11k+6, k>1$




www.pisethsok.wordpress.com

សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

- ដោយដឹងថា គេបានរៀបគ្រាប់ផ្លែស្វាយជា 17 គំនរស្មើៗគ្នា និងគ្មានសល់ផ្លែស្វាយ នោះគេបាន :

$M \equiv 0 \pmod{17} \Rightarrow M = 11k + 6 \equiv 0 \pmod{17}$ ៥ពិន្ទុ

$\Rightarrow 11k \equiv -6 \equiv 11 \pmod{17}$

ដើម្បីបានចំនួនផ្លែស្វាយតិចបំផុតដែលគេបានបេះ គេត្រូវតែយក $m = 1$ ជាការស្រេច : ៥ពិន្ទុ

$m = 1 \Rightarrow k = 18$ ហើយ $M = 11 \cdot 18 - 6 = 204$ ផ្លែ

V. (២០ពិន្ទុ) គេសន្មត់ថាដីមុំឡិចតុកោណ ABCD មានផ្ទៃក្រឡាអតិបរមា



៥ពិន្ទុ

- គេផ្ទៃក្រឡានៃ ABCD ជាអនុគមន៍នៃ $a; b; c; d; x$ និង $y$

ចតុកោណ ABCD មានផ្ទៃក្រឡា $S = \frac{1}{2}ab\sin x + \frac{1}{2}cd\sin y$

អង្កត់ទ្រូង $[AC]$ មានប្រវែង $L = a^2 + b^2 - 2ab\cos x = c^2 + d^2 - 2cd\cos y$ ៥ពិន្ទុ

ដោយគេដេរីវេធៀបនឹង $x$ គេបាន :

$S'(x) = \frac{1}{2}ab\cos x + \frac{1}{2}cd\cos y \cdot y'$ (1)

$L'(x) = 2ab\sin x = 2cd\sin y \cdot y'$

$ab\sin x = cd\sin y \cdot y' \Rightarrow y' = \frac{ab\sin x}{cd\sin y}$ ៥ពិន្ទុ

$(1) \Rightarrow S'(x) = \frac{1}{2}ab \times \frac{\sin x\cos y + \cos x\sin y}{\sin y} = \frac{1}{2}ab \times \frac{\sin(x - y)}{\sin y}$ មានសញ្ញាដូចសញ្ញា $\sin(x - y)$

$S'(x) = 0 \Leftrightarrow \sin(x + y) = 0 \Leftrightarrow x + y = \pi$

បើ $0 < x + y < \pi \Leftrightarrow S'(x) > 0$

បើ $2\pi > x + y > \pi \Leftrightarrow S'(x) < 0$ ៥ពិន្ទុ

បានន័យថា $S(x)$ មានអតិបរមាលុះត្រាតែ $x + y = \pi$

ដូចនេះ ចតុកោណ ABCD មានផ្ទៃក្រឡាអតិបរមាលុះត្រាតែ ABCD ចារឹកក្នុងរង្វង់មួយ ។

VI. (២០ពិន្ទុ) តាង $a = \frac{1+\sqrt{5}}{2}$ និង $b = \frac{1-\sqrt{5}}{2}$ ។

១. បង្ហាញថា $u_n > a^{n-2}$ ចំពោះគ្រប់ចំនួនគត់ $n \geq 3$

- ចំពោះ $n = 3$ គេបាន $u_3 = 2$ ហើយ $a^{3-2} = a = \frac{1+\sqrt{5}}{2} < 2$ បានន័យថា $u_3 > a^{3-2}$

- ឧបមាថា $u_p > a^{p-2}$ ចំពោះ $p \geq 3$ ៥ពិន្ទុ



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

- សិក្សាចំពោះ $p+1$

តាមសម្មតិកម្មអនុមានរួម គេបាន $u_p > a^{p-2}, u_{p-1} > a^{p-3}$

[illegible]

តែគេដឹងថា $a = \frac{1+\sqrt{5}}{2}$ ជាឫសនៃសមីការ $x^2 = x+1$ នោះគេបាន $a^2 = a+1$

ដោយគុណនឹង $a^{p-3}$ គេបាន $a^{p-1} = a^{p-2} + a^{p-3}$ (2)

តាម $(1) \& (2) \Rightarrow u_{p+1} > a^{p+1-2}$ ពិន្ទុ

ដូចនេះ $u_n > a^{n-2}$ ចំពោះគ្រប់ចំនួនគត់ $n \geq 3$ ។

ខ. បង្ហាញថា $u_n = \frac{1}{\sqrt{5}}(a^n - b^n)$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ :

- ចំពោះ $n = 1$ គេបាន $1 = u_1 = \frac{1}{\sqrt{5}}(a-b) = \frac{1}{2\sqrt{5}}(1+\sqrt{5}-1+\sqrt{5}) = 1$

- ឧបមាថា $u_k = \frac{1}{\sqrt{5}}(a^k - b^k)$ ពិន្ទុ

- សិក្សាចំពោះ $k+1$

គេមាន $u_{k+1} = u_k + u_{k-1} = \frac{1}{\sqrt{5}}\left((a^k + a^{k-1}) - (b^k + b^{k-1})\right)$ (3)

តែ $a \& b$ ជាឫសនៃសមីការ $x^2 = x+1$ នោះ $a^2 = a+1$ និង $b^2 = b+1$

គេបាន $a^{k+1} = a^k + a^{k-1}$ និង $b^{k+1} = b^k + b^{k-1}$

តាម $(3) \Rightarrow u_{k+1} = \frac{1}{\sqrt{5}}(a^{k+1} - b^{k+1})$ ពិន្ទុ

ដូចនេះ $u_n = \frac{1}{\sqrt{5}}(a^n - b^n)$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។

www.pisethsok.wordpress.com

ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១០

ប្រធានក្រុមកំណែវិញ្ញាសា គណិតវិទ្យា ថ្នាក់ទី ១២

អ៊ី សៀងលី



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

# ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

## ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា រូបវិទ្យា ថ្នាក់ទី ៩ និងថ្នាក់ទី ១២

សម័យប្រឡង: ០១.០៤ ២០១០

វិញ្ញាសា គណិតវិទ្យា ថ្នាក់ទី ១២ លើកទី២ ថ្ងៃទី ០៣.០៤.២០១០

**រយៈពេល ១៨០ នាទី ពិន្ទុ ១០០**

I.(១០ពិន្ទុ) សមីការ $ax^2+2010x+c=x$ គ្មានឫសទេនៅក្នុងសំណុំចំនួនពិត ។

បង្ហាញថា សមីការ $a\left(ax^2-2010x+c\right)^2+2010\left(ax^2+2010x+c\right)+c=x$ គ្មានឫសនៅក្នុងសំណុំចំនួនពិតដែរ ។

II.(១៥ពិន្ទុ) ពហុធា $P(x)=x^n+a_1x^{n-1}+a_2x^{n-2}+\cdots+a_{n-1}x+1$ មានមេគុណ $a_1, a_2, \ldots, a_{n-1}$ ជាចំនួនមិនអវិជ្ជមាន ។

គេដឹងថាពហុធា $P(x)$ មាន $n$ ឫសដែលសុទ្ធតែជាចំនួនពិត ។

បង្ហាញថា $P(2010)\geq\left(2\sqrt{2010}\right)^n$ ។

III.(១៥ពិន្ទុ) គេឱ្យចំណុចនឹង $A$ មួយដែលស្ថិតនៅផ្ទៃក្នុងនៃមុំស្រួច $\angle xOy$ មួយ ។

រកចំណុច $B$ និង $C$ នៅលើជ្រុង $[Ox)$ និង $[Oy)$ រៀងគ្នា ដើម្បីឱ្យត្រីកោណ $ABC$ មានបរិមាត្រអប្បបរមា ។

IV.(២០ពិន្ទុ) គេមានចំនួនគត់វិជ្ជមាន $r$ ដែលជាសំណល់ក្នុងវិធីចែកអឺគ្លីតនៃចំនួនគត់វិជ្ជមាន $a$ និង $b$ ។

១. បង្ហាញថា $2^r-1$ ជាសំណល់ក្នុងវិធីចែកអឺគ្លីតនៃចំនួនគត់វិជ្ជមាន $2^a-1$ និង $2^b-1$ ។

២. គេតាង $\mu$ ជាតួចែករួមធំបំផុតនៃ $a$ និង $b$ ។ បង្ហាញថា $2^\mu-1$ ជាតួចែករួមធំបំផុតនៃ $2^a-1$ និង $2^b-1$ ។

V.(២០ពិន្ទុ) ស្វ៊ែ $(S)$ មួយមានកាំ $R$ ហើយចារឹកក្នុងតេត្រាអែត $ABCD$ មួយ ។ ប្លង់បួនផ្សេងគ្នាប៉ះនឹងស្វ៊ែ $(S)$ ហើយស្របរៀងគ្នានឹងមុខទាំងបួននៃតេត្រាអែត កាត់តេត្រាអែតនោះបានជាតេត្រាអែតតូចៗចំនួនបួន។ តេត្រាអែតតូចៗទាំងនោះចារឹកក្រៅស្វ៊ែតូចៗ ដែលមានកាំរៀងគ្នា $r_1$ , $r_2$ , $r_3$ និង $r_4$ ។

បង្ហាញថា $r_1+r_2+r_3+r_4=2R$ ។

VI.(២០ពិន្ទុ) អនុគមន៍ $f$ មួយកំណត់ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $x$ ហើយ ផ្ទៀងផ្ទាត់លក្ខខណ្ឌទាំងបីខាងក្រោម:

(i) $f$ ជាអនុគមន៍កើនដាច់ខាតលើចន្លោះ $]0;+\infty[$

(ii) $f(x)>-\dfrac{1}{x}$ ចំពោះគ្រប់ $x>0$

(iii) $f(x)\cdot f\left(f(x)+\dfrac{1}{x}\right)=1$ ចំពោះគ្រប់ $x>0$ ។

១. គណនា $f(1)$ ។

២. គណនា $f(x)$ ។

សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

I. (១០ពិន្ទុ) បង្ហាញថា សមីការ $a\left(ax^2+2010x+c\right)^2+2010\left(ax^2+2010x+c\right)+c=x$ គ្មានឫសជាចំនួនពិតដែរ :

តាង $t(x)=ax^2+2010x+c$

ដោយសមីការ $t(x)=x$ គ្មានឫសជាចំនួនពិត នោះ ឬមួយ $t(x)<x$ ឬមួយ $t(x)>x$ ចំពោះគ្រប់ចំនួនពិត $x$ ។ ៥ពិន្ទុ

គេទាញបាន ឬមួយ $t(t(x))<t(x)<x$ ឬមួយ $t(t(x))>t(x)>x$ ចំពោះគ្រប់ចំនួនពិត $x$ ។ បានន័យថា :

- ឬមួយ $a\left(ax^2+2010x+c\right)^2+2010\left(ax^2+2010x+c\right)+c<x$ ចំពោះគ្រប់ចំនួនពិត $x$
- ឬមួយ $a\left(ax^2+2010x+c\right)^2+2010\left(ax^2+2010x+c\right)+c>x$ ចំពោះគ្រប់ចំនួនពិត $x$ ។ ៥ពិន្ទុ

ដូចនេះ សមីការ $a\left(ax^2+2010x+c\right)^2+2010\left(ax^2+2010x+c\right)+c=x$ គ្មានឫសជាចំនួនពិតដែរ ។

II. (១៥ពិន្ទុ) បង្ហាញថា $P(2010)\ge\left(2\sqrt{2010}\right)^n$ :

ដោយមេគុណ $a_1, a_2, \ldots, a_{n-1}$ ជាចំនួនមិនអវិជ្ជមាន នោះ ឫស $x_1, x_2, \ldots, x_n$ ជាចំនួនពិតមិនវិជ្ជមាន ។

តាង $\alpha_i=-x_i, i=1,2,\ldots,n$ នោះគេបាន $\alpha_i\ge 0$ ហើយ $P(x)=(x+\alpha_1)(x+\alpha_2)\cdots(x+\alpha_n)$ ៥ពិន្ទុ

$P(2010)=(2010+\alpha_1)(2010+\alpha_2)\ldots(2010+\alpha_n)$

ម្យ៉ាងទៀត $2010+\alpha_i\ge 2\sqrt{2010\cdot\alpha_i}, i=1,2,\ldots,n$ ៥ពិន្ទុ

គេបាន $P(2010)=(2010+\alpha_1)(2010+\alpha_2)\ldots(2010+\alpha_n)\ge 2^n\sqrt{2010^n\cdot\alpha_1\cdot\alpha_2\cdots\alpha_n}$

ដូចនេះ $P(2010)\ge\left(2\sqrt{2010}\right)^n$ ព្រោះ $\alpha_1\cdot\alpha_2\cdots\alpha_n=1$ ៥ពិន្ទុ

III. (១៥ពិន្ទុ) រកចំណុច B និង C នៅលើជ្រុង $[Ox)$ និង $[Oy)$ រៀងគ្នា ដើម្បីឱ្យត្រីកោណ ABC មានបរិមាត្រអប្បបរមា :




៥ពិន្ទុ

តាង M & N ជាចំណុចឆ្លុះនៃ A ចំពោះ $[Ox)$ និង $[Oy)$ រៀងគ្នា ។

តាង $B_0$ & $C_0$ ជាចំណុចប្រសព្វ រវាង $[MN]$ ជាមួយ $[Ox)$ និង $[Oy)$ រៀងគ្នា ។

យក $B_i\in[Ox), C_i\in[Oy), i=1,2,\ldots$

- គេបានបរិមាត្រនៃ $\Delta AB_0C_0 : p_0=AB_0+B_0C_0+C_0A=MB_0+B_0C_0+C_0N=MN$ : ថេរ ៥ពិន្ទុ
- គេបានបរិមាត្រនៃ $\Delta AB_iC_i : p_i=AB_i+B_iC_i+C_iA=MB_i+B_iC_i+C_iN$

តែ $MB_i+B_iC_i>MC_i\Rightarrow MB_i+B_iC_i+C_iN>MC_i+C_iN>MN$ ចំពោះគ្រប់ $i=1,2,\ldots$

គេបាន $p_i>p_0, \forall i=1,2,\ldots$

ដូចនេះ ត្រីកោណ ABC មានបរិមាត្រអប្បបរមាកាលណា $B=B_0, C=C_0$ ។ ៥ពិន្ទុ




សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

(២០ពិន្ទុ) ១. បង្ហាញថា $2^r - 1$ ជាសំណល់ក្នុងវិធីចែកអឺគ្លីតនៃចំនួនគត់វិជ្ជមាន $2^a - 1$ និង $2^b - 1$ :

តាមវិធីចែកអឺគ្លីត $a = bq + r, 0 < r < b$ គេបាន :

$2^a - 1 = 2^{bq+r} - 2^r + 2^r - 1 = 2^r(2^b - 1)((2^b)^{q-1} + \dots + 2^b + 1) + (2^r - 1)$ ៥ពិន្ទុ

$= (2^b - 1)(2^{b(q-1)+r} + \dots + 2^{b+r} + 2^r) + 2^r - 1, 0 < 2^r - 1 < 2^b - 1$

ដូចនេះ $2^r - 1$ ជាសំណល់ក្នុងវិធីចែកអឺគ្លីតនៃចំនួនគត់វិជ្ជមាន $2^a - 1$ និង $2^b - 1$ ៥ពិន្ទុ

២. បង្ហាញថា $2^d - 1$ ជាតួចែករួមធំបំផុតនៃ $(2^a - 1)$ និង $(2^b - 1)$ :

តាង $r_0 = a, r_1 = b$ ។ តាមវិធីចែកអឺគ្លីតបន្តបន្ទាប់ :

$r_0 = r_1q_1 + r_2\ (0 < r_2 < r_1), r_1 = r_2q_2 + r_3\ (0 \le r_3 < r_2), \dots, r_{n-3} = r_{n-2}q_{n-2} + r_{n-1}\ (0 \le r_{n-1} < r_{n-2})$

$r_{n-2} = r_{n-1}q_{n-1}$

គេបាន $\gcd(a,b) = r_{n-1} = d$ ៥ពិន្ទុ

តាង $R_0 = 2^a - 1, R_1 = 2^b - 1$ ។ តាមវិធីចែកអឺគ្លីតបន្តបន្ទាប់ និងលទ្ធផលខាងលើ :

$R_0 = R_1Q_1 + R_2, R_2 = 2^{r_2} - 1$

$R_1 = R_2Q_2 + R_3, R_3 = 2^{r_3} - 1$

..........................................

$R_{n-3} = R_{n-2}Q_{n-2} + R_{n-1}, R_{n-1} = 2^{r_{n-1}} - 1$

$R_{n-2} = R_{n-1}Q_{n-1}$ ៥ពិន្ទុ

គេបាន $\gcd(R_0, R_1) = R_{n-1} = 2^d - 1$

V. (២០ពិន្ទុ) បង្ហាញថា $r_1 + r_2 + r_3 + r_4 = 2R$ :



៥ពិន្ទុ

តាង $f_i$ & $h_i$, $i = 1,2,3,4$ ជាផ្ទៃក្រឡានៃមុខ និងកម្ពស់ដែលត្រូវគ្នានៃតេត្រាអែត។

តាង $r_i, i = 1,2,3,4$ ជាកាំស្វ៊ែចារឹកក្នុងតេត្រាអែតតូចៗទាំងបួន។

ដោយប្លង់មុខកាត់ស្របមុខនៃតេត្រាអែត នោះតេត្រាអែតតូចៗដែលបានទាំងបួន ដូចនឹងតេត្រាអែតដើម។

គេបាន $R/r_i = (h_i - 2R)/h_i = 1 - (2R/h_i) \Rightarrow (2R/h_i) = 1 - (r_i/R) = (R - r_i)/R$ ៥ពិន្ទុ

ហើយ $2R/h_i = (R - r_i)/R \Rightarrow 1/h_i = (R - r_i)/2R^2, i = 1,2,3,4$

ចំពោះ $i = 1,2,3,4$ គេបាន $1/h_1 + 1/h_2 + 1/h_3 + 1/h_4 = (4R - r_1 - r_2 - r_3 - r_4)/2R^2$ (1)

ម្យ៉ាងទៀតមាឌនៃតេត្រាអែត $V = (1/3)R(f_1 + f_2 + f_3 + f_4) \Rightarrow f_1 + f_2 + f_3 + f_4 = 3V/R$

$V = (1/3)f_1h_1 = (1/3)f_2h_2 = (1/3)f_3h_3 = (1/3)f_4h_4$ ៥ពិន្ទុ

$1/h_1 = f_1/3V, 1/h_2 = f_2/3V, 1/h_3 = f_3/3V, 1/h_4 = f_4/3V$


សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeachingSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS www.pisethsok.wordpress.com គ្រូបង្រៀនគណិតវិទ្យា

គេបាន $1/h_1 + 1/h_2 + 1/h_3 + 1/h_4 = (f_1 + f_2 + f_3 + f_4)/3V = (3V/R):3V = 1/R$ (2)

តាម (1) & (2) $\Rightarrow (4R - r_1 - r_2 - r_3 - r_4)/2R^2 = 1/R$ ហើយ $4R - r_1 - r_2 - r_3 - r_4 = 2R$ ៥ពិន្ទុ

ដូចនេះ $r_1 + r_2 + r_3 + r_4 = 2R$ ។

II. ២ពិន្ទុ ក. គណនា f(1)

តាង $t = f(1)$

- យក $x = 1 \Rightarrow f(1)\cdot f(f(1)+1) = 1$ ហើយ $t\cdot f(t+1) = 1 \Rightarrow f(t+1) = 1/t$

- យក $x = t+1 \Rightarrow f(t+1)f(f(t+1)+1/(t+1)) = 1$ ហើយ $(1/t)f(1/t+1/(t+1)) = 1$

គេបាន $f(1/t + 1/(t+1)) = t = f(1)$ ៥ពិន្ទុ

ដោយ f ជាអនុគមន៍កើនដាច់ខាតលើចន្លោះ $]0;+\infty[$ នោះគេបាន $1/t + 1/(1+t) = 1$ សមមូល $t^2 - t - 1 = 0$

មានឬស $t = (1 \pm \sqrt{5})/2$

- ចំពោះ $t = (1+\sqrt{5})/2$ គេបាន $1 < t = f(1) < f(1+t) = 1/t < 1$ ជាករណីមិនអាចទៅរួច

- ចំពោះ $t = (1-\sqrt{5})/2$ គេបាន $t = f(1) > -1/1$ គឺពិតចំពោះ (ii) ៥ពិន្ទុ

ដូចនេះ $f(1) = (1-\sqrt{5})/2$

ខ. គណនា f(x)

តាង $\alpha = f(x) \Rightarrow \alpha\cdot f(\alpha + 1/x) = 1 \Rightarrow f(\alpha + 1/x) = 1/\alpha$

- យក $x = \alpha + 1/x \Rightarrow f(\alpha + 1/x)\cdot f(f(\alpha + 1/x) + 1/(\alpha + 1/x)) = 1$

គេទាញបាន $f(f(\alpha + 1/x) + x/(\alpha x + 1)) = \alpha = f(x)$

ដោយ f ជាអនុគមន៍កើនដាច់ខាតលើចន្លោះ $]0;+\infty[$ នោះគេបាន $f(\alpha + 1/x) + x/(\alpha x + 1) = x$

$1/\alpha + x/(\alpha x + 1) = x \Leftrightarrow x^2\alpha^2 - x\alpha - 1 = 0$ ៥ពិន្ទុ

$\alpha = (1 \pm \sqrt{5})/2x$

- ចំពោះ $\alpha = (1+\sqrt{5})/2x \Rightarrow f'(x) = -(1+\sqrt{5})/2x^2 < 0$

ដូចនេះ f ជាអនុគមន៍ចុះ ដែលផ្ទុយពីលក្ខណៈ (i)

- ចំពោះ $\alpha = (1-\sqrt{5})/2x \Rightarrow f'(x) = -(1-\sqrt{5})/2x^2 > 0$

ដូចនេះ f ជាអនុគមន៍កើន ដែលផ្ទៀងផ្ទាត់លក្ខណៈ (i)

ម្យ៉ាងទៀត $(1-\sqrt{5})/2 > -1 \Rightarrow f(x) = (1-\sqrt{5})/2x > -1/x$ ដែលផ្ទៀងផ្ទាត់លក្ខណៈ (ii) ។

ដោយ $f(x) = t/x$ នោះគេបាន :

$$f(x)\cdot f\left(f(x) + \frac{1}{x}\right) = (t/x)f((t/x) + (1/x)) = (t/x)(tx/t+1) = t^2/(t+1) = 1$$ ៥ពិន្ទុ

ដែលផ្ទៀងផ្ទាត់លក្ខណៈ (iii) ។

ដូចនេះ $f(x) = t/x$ ដែល $t = (1-\sqrt{5})/2$ ។

ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១០

ប្រធានក្រុមកែវិញ្ញាសាគណិតវិទ្យា ថ្នាក់ទី១២

អ៊ុំ សំអឿន


ផ្ទះពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

**ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស**

**ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា រូបវិទ្យា ថ្នាក់ទី៩ និងថ្នាក់ទី១២**

**សម័យប្រឡង : ០១ មេសា ២០១១**

**វិញ្ញាសា: គណិតវិទ្យា ថ្នាក់ទី១២ លើកទី១ : ០១.៤.២០១១**

**រយៈពេល: ១៨០ នាទី ពិន្ទុ: ១០០**

I. (១០ពិន្ទុ) នៅដើមឆ្នាំ ២០១១ នេះ ចំនួនទេសចរដែលបានមកទស្សនាប្រាសាទអង្គរវត្តស្មើនឹង $pq(p^2-q^2)$ ដែល $p$ និង $q$ ជាចំនួនគត់ធម្មជាតិ ហើយ $p>q$ ។ គេស្រង់ឈ្មោះទេសចរទាំងនោះដាក់ក្នុងបញ្ជីមួយដោយមានចុះលេខរៀងត្រឹមត្រូវ។ បង្ហាញថា លេខរៀងរបស់ទេសចរចុងក្រោយគេបង្អស់ជាពហុគុណនៃ 3 ។

II. (១០ពិន្ទុ) ចំណុច $M_i(x,y,z)$ មានកូអរដោនេជាចំនួនគត់រ៉ឺឡាទីបដែលផ្ទៀងផ្ទាត់ $x^2+y^2+z^2=x^3+y^3+z^3$ ។ បង្ហាញថា មានចំណុច $M_i(x,y,z)$ ច្រើនរាប់មិនអស់នៅក្នុងលំហ។

III. (២០ពិន្ទុ) ស្វ៊ីត $(u_n)$ កំណត់ដោយ $u_1=1, u_2=1$ និង $u_{n+1}=u_n+u_{n-1}$ ចំពោះ $n\geq 2$ ។
បង្ហាញថា $u_{2011}u_{2012}-u_{2010}u_{2013}=1$ ហើយ $u_{1042012}u_{1042013}-u_{1042011}u_{1042014}=-1$ ។

IV. (២០ពិន្ទុ) ស្វ៊ីត $(I_k)$ កំណត់ដោយ $I_k=\int_0^{\pi/2}\sin^k x\,dx$ ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $k$ ។ អនុគមន៍ $f$ កំណត់ដោយ $f(k)=(k+1)I_kI_{k+1}$ ។

១_ កំណត់ទំនាក់ទំនងរវាង $I_k$ និង $I_{k+2}$ ។

២_ ប្រៀបធៀប $f(k)$ និង $f(k+1)$ ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $k$ ។ គណនាតម្លៃ $f(2011)$ ។

V. (២០ពិន្ទុ) ចតុកោណប៉ោង $ABCD$ មួយមានជ្រុង $AB=a, BC=b, CD=c, DA=d$ និងបរិមាត្រ $2p$ ហើយចារឹកក្នុងរង្វង់មួយ។
បង្ហាញថា ចតុកោណ $ABCD$ មានផ្ទៃក្រឡា $S=\sqrt{(p-a)(p-b)(p-c)(p-d)}$ ។

VI. (២០ពិន្ទុ) $P_n(x)$ ជាពហុធាដឺក្រេ $n$ ដែលផ្ទៀងផ្ទាត់ $P_n(x)=-2xP_{n-1}(x)+P'_{n-1}(x)$ ។

១_ បង្ហាញថាដេរីវេទី $n$ នៃអនុគមន៍ $y=e^{-x^2}$ កំណត់ដោយ $y^{(n)}=e^{-x^2}P_n(x)$ ។

២_ ទាញបញ្ជាក់ថា $P_{n+1}(x)+2xP_n(x)+2nP_{n-1}(x)=0$ ហើយ $P''_n(x)-2xP'_n(x)+2nP_n(x)=0$ ។

www.pisethsok.wordpress.com

សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

# ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

## ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា រូបវិទ្យា ថ្នាក់ទី ៩ និងទី ១២

## សម័យប្រឡង: ០១.០៤.២០១១

## អត្រាកំណែគណិតវិទ្យា ថ្នាក់ទី ១២ លើកទី ១ ថ្ងៃទី ០១.០៤.២០១១

## រយៈពេល ១៨០នាទី ពិន្ទុ ១០០

I-(១០ពិន្ទុ) បង្ហាញថា លេខរៀងនៃទេសចរចុងក្រោយគេបង្អស់ជាពហុគុណនៃ3 ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $p, q, p > q$ :

គេត្រូវបង្ហាញថា $A = pq(p^2 - q^2)$ ជាពហុគុណនៃ3 ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $p, q, p > q$ ។

គេមាន $A = pq(p^2 - q^2) = pq(p-q)(p+q)$

ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $p, q$ គេអាចមានករណី :

$p = 3a$ ឬ $p = 3a+1$ ឬ $p = 3a+2$ ដែល $a$ ចំនួនគត់ធម្មជាតិ

$q = 3b$ ឬ $q = 3b+1$ ឬ $q = 3b+2$ ដែល $b$ ចំនួនគត់ធម្មជាតិ

គេសិក្សាករណីនីមួយៗដូចខាងក្រោម :

-បើ $p = 3a \Rightarrow A$ ជាពហុគុណនៃ3 1P

-បើ $p = 3a+1$ 1P

.បើ $q = 3b \Rightarrow A$ ជាពហុគុណនៃ3 1P

.បើ $q = 3b+1 \Rightarrow p - q = 3(a-b) \Rightarrow A$ ជាពហុគុណនៃ3 1P

.បើ $q = 3b+2 \Rightarrow p + q = 3(a+b+1) \Rightarrow A$ ជាពហុគុណនៃ3 1P

-បើ $p = 3a+2$ 1P

.បើ $q = 3b \Rightarrow A$ ជាពហុគុណនៃ3 1P

.បើ $q = 3b+1 \Rightarrow p + q = 3(a+b+1) \Rightarrow A$ ជាពហុគុណនៃ3 1P

.បើ $q = 3b+2 \Rightarrow p - q = 3(a-b) \Rightarrow A$ ជាពហុគុណនៃ3 1P

ដូចនេះ លេខរៀងនៃទេសចរចុងក្រោយគេបង្អស់ជាពហុគុណនៃ3 ។ 1P

II-(១០ពិន្ទុ) បង្ហាញថាមានចំណុច $M_i(x, y, z)$ ច្រើនរាប់មិនអស់នៅក្នុងលំហ :

ដើម្បីបំបាត់ $x^3$ និង $z^3$ ពីអង្គទី២ គេអាចយក $z = -x$ ។ 2P

នោះគេបាន $2x^2 + y^2 = y^3 \Leftrightarrow 2x^2 = (y-1)y^2$ 1P

$\Leftrightarrow x^2 = \dfrac{y-1}{2} \cdot y^2$ 1P

សមីការផ្ទៀងផ្ទាត់លុះត្រាតែ $\dfrac{y-1}{2}$ ជាការេប្រាកដ គឺថា $\dfrac{y-1}{2} = k^2, k \in Z \Rightarrow y = 2k^2 + 1$ 2P

គេបាន $2x^2 = (2k^2 + 1 - 1)(2k^2 + 1)^2$ ឬ $x^2 = k^2(2k^2 + 1)^2$ 1P

ហើយ $x = \pm k(2k^2 + 1), y = 2k^2 + 1, z = \mp k(2k^2 + 1)$ ដែល $k \in Z$ ។ 2P

ដូចនេះ មានចំណុច $M_i(x, y, z)$ ច្រើនរាប់មិនអស់នៅក្នុងលំហ ។ 1P

III-(២០ពិន្ទុ) ស្វ៊ីត $(u_n)$ កំណត់ដោយ $u_1 = 1, u_2 = 1$ និង $u_{n+1} = u_n + u_{n-1}, n \geq 2$ ។

បង្ហាញថា $u_{2011} u_{2012} - u_{2010} u_{2013} = 1$



សុខ ពិសិដ្ឋ www.pisethsok.wordpress.com គ្រូបង្រៀនគណិតវិទ្យា

សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

បង្ហាញថា $u_{1042012}u_{1042013}-u_{1042011}u_{1042014}=-1$

ដំបូងគេត្រូវបង្ហាញថា $u_{n+1}u_{n+2}-u_nu_{n+3}=(-1)^n$ ចំពោះគ្រប់ $n\in N$

-ចំពោះ $n=1$ គេបាន $u_2u_3-u_1u_4=1\cdot 2-1\cdot 3=(-1)^1$ : សមភាពពិត 3p

-ឧបមាថាសមភាពពិតដល់ $n=p$ គឺថា $u_{p+1}u_{p+2}-u_pu_{p+3}=(-1)^p$ 3p

-សិក្សា ចំពោះ $n=p+1$

$u_{p+1+1}u_{p+1+2}-u_{p+1}u_{p+1+3}=u_{p+2}u_{p+3}-u_{p+1}u_{p+4}$

$u_{p+2}u_{p+3}-u_{p+1}u_{p+4}=u_{p+2}(u_{p+2}+u_{p+1})-u_{p+1}(u_{p+3}+u_{p+2})$ 2p

$=(u_{p+2})^2+u_{p+2}u_{p+1}-u_{p+1}(u_{p+2}+u_{p+1}+u_{p-2})=(u_{p+2})^2-(u_{p+1})^2-(u_{p+1}u_{p+2})$ 2p

$=(u_{p+2}-u_{p+1})(u_{p+2}+u_{p+1})-(u_{p+1}u_{p+2})$

$=(u_p+u_{p+1}-u_{p-1})(u_{p+3})-(u_{p-1}u_{p+2})=u_pu_{p+3}-u_{p+1}u_{p+2}$ 2p

$=(-1)(u_{p+1}u_{p+2}-u_pu_{p+3})=(-1)(-1)^p=(-1)^{p+1}$ 2p

បញ្ជាក់ថាសមភាពពិតចំពោះ $n=p+1$ ។

ដូចនេះ $u_{n+1}u_{n+2}-u_nu_{n+3}=(-1)^n$ ចំពោះគ្រប់ $n\in N$ ។ 2p

- បង្ហាញថា $u_{2011}u_{2012}-u_{2010}u_{2013}=1$

ដោយយក $n=2010$ នោះគេបាន $u_{2011}u_{2012}-u_{2010}u_{2013}=(-1)^{2010}=1$ 2p

- បង្ហាញថា $u_{1042012}u_{1042013}-u_{1042011}u_{1042014}=-1$

ដោយយក $n=1042011$ នោះគេបាន $u_{1042012}u_{1042013}-u_{1042011}u_{1042014}=(-1)^{1042011}=-1$ 2p

IV-(២០ពិន្ទុ) ១-កំណត់ទំនាក់ទំនងរវាង $I_k$ និង $I_{k+2}$ ៨ពិន្ទុ

គេមាន $I_k=\int_0^{\pi/2}\sin^{k-1}x\sin x\,dx=\left[-\cos x\sin^{k-1}x\right]_0^{\pi/2}+(k-1)\int_0^{\pi/2}\sin^{k-2}x\cos^2 x\,dx$ 2p

$I_k=(k-1)\int_0^{\pi/2}\sin^{k-2}x(1-\sin^2 x)dx=(k-1)I_{k-2}-(k-1)I_k$ 2p

$\Rightarrow kI_k=(k-1)I_{k-2}$ 2p

$\Rightarrow (k+2)I_{k+2}=(k+1)I_{k+2-2}\quad\Rightarrow (k+2)I_{k+2}=(k+1)I_k$ 2p

២- ប្រៀបធៀប $f(k)$ និង $f(k+1)$ ១២ពិន្ទុ

គេមាន

$f(k+1)=(k+1+1)I_{k+1}I_{k+1+1}$

$f(k+1)=(k+2)I_{k+1}I_{k+2}\qquad(1)$ 2p

តែ $(k+2)I_{k+2}=(k+1)I_k\Rightarrow I_{k+2}=\dfrac{k+1}{k+2}I_k$ 2p

តាម (1) គេបាន $f(k+1)=(k+2)I_{k+1}\dfrac{k+1}{k+2}I_k$

$f(k+1)=(k+1)I_{k+1}I_k$ 1p

ដោយ $f(k)=(k+1)I_kI_{k+1}$ ហើយ $f(k+1)=(k+1)I_kI_{k+1}$

នោះគេទាញបាន $f(k+1)=f(k)\,,\forall k\in N$ 1p

គណនាតម្លៃ $f(2011)$ :

ដោយ $f(k+1)=f(k)\,,\forall k\in N$ នោះគេអាចសរសេរ :



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

$f(k)=f(k-1)=f(k-2)=\cdots=f(2)=f(1)=(1+1)I_1I_2=2I_1I_2\ \ (2)$ 2p

តែ $I_1=\int_0^{\pi/2}\sin x\,dx=\left[-\cos x\right]_0^{\pi/2}=1$ 1p

$I_2=\int_0^{\pi/2}\sin^2 x\,dx=(1/2)\int_0^{\pi/2}(1-\cos 2x)dx=(1/2)\left[x-(1/2)\sin 2x\right]_0^{\pi/2}=\pi/4$ 1p

តាម(2) គេបាន $f(k)=\pi/2\Rightarrow f(2011)=\pi/2$ ។ 2p

V-(២០ពិន្ទុ) បង្ហាញថា ចតុកោណ $ABCD$ មានផ្ទៃក្រឡា $S=\sqrt{(p-a)(p-b)(p-c)(p-d)}$




2p

តាមទ្រឹស្តីបទ កូស៊ីនុសក្នុង $\Delta ABC$ និង $\Delta ACD$ :

2p

$AC^2=a^2+b^2-2ab\cos B=c^2+d^2-2cd\cos D$ ព្រោះ $B+D=\pi\Rightarrow\cos D=-\cos B$

$a^2+b^2-2ab\cos B=c^2+d^2+2cd\cos B$ 1p

$\cos B=\dfrac{a^2+b^2-c^2-d^2}{2(ab+cd)}$ 1p

ម្យ៉ាងទៀត

$S(ABCD)=S(ABC)+S(ACD)$

$=(1/2)ab\sin B+(1/2)cd\ \sin D$ 2p

$S(ABCD)=(1/2)ab\sin B+(1/2)cd\ \sin B$ ព្រោះ $B+D=\pi\Rightarrow\sin D=\sin B$ 1p

$S(ABCD)=(1/2)(ab+cd)\sin B$ 1p

$S(ABCD)=(1/2)(ab+cd)\sqrt{1-\cos^2 B}\qquad(1)$ 1p

តែគេមាន :

$1-\cos^2 B=\left(1+\dfrac{a^2+b^2-c^2-d^2}{2(ab+cd)}\right)\left(1-\dfrac{a^2+b^2-c^2-d^2}{2(ab+cd)}\right)$ 2p

$=\left(\dfrac{2(ab+cd)+a^2+b^2-c^2-d^2}{2(ab+cd)}\right)\left(\dfrac{2(ab+cd)-a^2-b^2+c^2+d^2}{2(ab+cd)}\right)$ 1p

$=\left(\dfrac{(a+b)^2-(c-d)^2}{2(ab+cd)}\right)\left(\dfrac{(c+d)^2-(a-b)^2}{2(ab+cd)}\right)$ 1p

$=\left(\dfrac{1}{4(ab+cd)^2}\right)(a+b+c-d)(a+b-c+d)(c+d+a-b)(c+d-a+b)$ 1p

$=\left(\dfrac{1}{4(ab+cd)^2}\right)(a+b+c+d-2d)(a+b+c+d-2c)(c+d+a+b-2b)(c+d-2a+a+b)$ 1p

ដោយតាង $2p=a+b+c+d$ នោះគេបាន :

ដោយតាង $2p=a+b+c+d$ នោះគេបាន :



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

$$1-\cos^2 B=\left(\frac{1}{4(ab+cd)^2}\right)(2p-2d)(2p-2c)(2p-2b)(2p-2a)$$

$$1-\cos^2 B=\left(\frac{4}{(ab+cd)^2}\right)(p-a)(p-b)(p-c)(p-d)$$ 1p

តាម (1) គេបាន :

$$S(ABCD)=\frac{1}{2}(ab+cd)\sqrt{\left(\frac{4}{(ab+cd)^2}\right)(p-a)(p-b)(p-c)(p-d)}$$ 2p

ដូចនេះ $S(ABCD)=\sqrt{(p-a)(p-b)(p-c)(p-d)}$ ដែល $p=(a+b+c+d)/2$ ។

VI- (២០ពិន្ទុ) $P_n(x)$ ជាពហុធាដឺក្រេ $n$ ដែលផ្ទៀងផ្ទាត់ $P_n(x)=-2xP_{n-1}+P'_{n-1}$

១-បង្ហាញថា $y^{(n)}=e^{-x^2}P_n(x)$ ៨ពិន្ទុ

-ចំពោះ $n=1$ គេបាន $y'=(-2x)e^{-x^2}=e^{-x^2}P_1(x)$ 2p

-ឧបមាថាសមភាពពិតដល់ $n=k$ គឺថា $y^{(k)}=e^{-x^2}P_k(x)$ (1) 2p

-សិក្សាចំពោះ $n=k+1$ : ដោយរកដេរីវេអង្គទាំងពីររបស់ (1) :

$y^{(k+1)}=e^{-x^2}\left(-2xP_k(x)+P'_k(x)\right)=e^{-x^2}P_{k+1}(x)$ 4p

២-ទាញបញ្ជាក់ថា $P_{n+1}(x)+2xP_n(x)+2nP_{n-1}(x)=0$ ហើយ $P''_n(x)-2xP'_n(x)+2nP_n(x)=0$ ១២ពិន្ទុ

គេមាន $y'=(-2x)e^{-x^2}=-2xy\Rightarrow y'+2xy=0$ (2) 2p

ដោយរកដេរីវេអង្គទាំងពីររបស់ (2) ចំនួន $n$ ដង និង ប្រើរូបមន្ត Leibniz :

$$(fg)^{(n)}=f^{(n)}g+C(n,1)f^{(n-1)}g'+\cdots+C(n,p)f^{(n-p)}g^{(p)}+\cdots+fg^{(n)}=\sum_{i=0}^{n}C(n,i)f^{(n-i)}g^{(i)}$$

គេបាន $y^{(n+1)}+2(xy)^{(n)}=y^{(n+1)}+2xy^{(n)}+2ny^{(n-1)}=0$ 2p

ឬ $e^{-x^2}(P_{n+1}(x)+2xP_n(x)+2nP_{n-1}(x))=0\Rightarrow P_{n+1}(x)+2xP_n(x)+2nP_{n-1}(x)=0$ (3) 2p

តែគេមាន : $P_{n+1}(x)=-2xP_n(x)+P'_n(x)$

តាម(3) គេបាន $-2xP_n(x)+P'_n(x)+2xP_n(x)+2nP_{n-1}(x)=0$

$P'_n(x)+2nP_{n-1}(x)=0\Rightarrow P'_n(x)=-2nP_{n-1}(x)$ 2p

$\Rightarrow P'_{n+1}(x)=-2(n+1)P_n(x)=-2nP_n(x)-2P_n(x)$ (4)

ដោយ $P_{n+1}(x)=-2xP_n(x)+P'_n(x)\Rightarrow P'_{n+1}(x)=-2xP'_n(x)-2P_n(x)+P''_n(x)$ (5) 2p

តាម (4) និង(5) គេបាន $P''_n(x)-2xP'_n(x)+2nP_n(x)=0$ 2p

ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១

ប្រធានក្រុមកំណែគណិតវិទ្យាថ្នាក់ទី ១២

អ៊ុំ សារឈី



សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

# ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

## ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា រូបវិទ្យា ថ្នាក់ទី៩ និងថ្នាក់ទី១២

## សម័យប្រឡង : ០១ មេសា ២០១១

## វិញ្ញាសា: គណិតវិទ្យា ថ្នាក់ទី១២ លើកទី២ : ០៣-៤-២០១១

## រយៈពេល: ១៨០ នាទី ពិន្ទុ: ១០០

I. (១០ពិន្ទុ) គេបានប្រើប្រាស់ឡានចំនួន 99 គ្រឿងសម្រាប់ដឹកជញ្ជូនកូនមាន់ចំនួន $7y38x5$ ក្បាល ទៅកាន់កសិដ្ឋានមួយ។
រកលេខ $x$ និង $y$ ក្នុងប្រព័ន្ធរាប់គោលដប់ដោយដឹងថាក្នុងឡាននីមួយៗមានចំនួនកូនមាន់ស្មើៗគ្នា។

II. (១០ពិន្ទុ) គេឱ្យចំនួនគត់រ៉ឺឡាទីប $\alpha,\beta,\lambda$ និង $\mu$ ដែលផ្ទៀងផ្ទាត់សមភាព $\alpha\mu=1+\beta\lambda$។ គេយក $x_0$ ជាតួចែករួមធំបំផុតនៃចំនួនគត់រ៉ឺឡាទីប $a$ និង $b$ ហើយយក $y_0$ ជាតួចែករួមធំបំផុតនៃ $\alpha a+\beta b$ និង $\lambda a+\mu b$។
ចូរប្រៀបធៀបចម្ងាយពីចំណុច $M_0(x_0,y_0)$ ទៅអ័ក្សទាំងពីរនៃតម្រុយអរតូណរម៉ាល់មួយ។

III. (២០ពិន្ទុ) គេឱ្យអនុគមន៍ពហុធា $f(x)=a_nx^n+a_{n-1}x^{n-1}+\cdots+a_1x+a_0$ ដែលមានលេខមេគុណជាចំនួនគត់រ៉ឺឡាទីប។
គេដឹងថាមានចំនួនគត់រ៉ឺឡាទីប $x_0$ ដែល $f(x_0)=p$ ជាចំនួនបឋម។
បង្ហាញថា មានចំនួនគត់រ៉ឺឡាទីប $\beta$ ច្រើនរាប់មិនអស់ ដែល $f(\beta)$ មិនមែនជាចំនួនបឋម។

IV. (២០ពិន្ទុ) ស្វ៊ីត $(x_n)$ កំណត់ដោយ $x_1=1, x_2=1$ និង $x_{n+1}=x_n+x_{n-1}$ ចំពោះ $n\ge 2$។
ស្វ៊ីត $(y_n)$ កំណត់ដោយ $y_n=|x_{n+4}x_{n-2}-x_{n+2}x_n|$ ចំពោះ $n\ge 3$។
ស្វ៊ីត $(z_n)$ កំណត់ដោយ $z_n-9=4x_{n-2}x_nx_{n-2}x_{n-4}$ ចំពោះ $n\ge 3$។
១-បង្ហាញថា $(y_n)$ ជាស្វ៊ីតថេរចំពោះ $n\ge 3$។ ទាញរកតម្លៃនៃតួ $y_{3042011}$។
២-បង្ហាញថា តួនីមួយៗនៃស្វ៊ីត $(z_n)$ ជាការេប្រាកដ។

V. (២០ពិន្ទុ) គេឱ្យ $a$ និង $X$ ជាចំនួនគត់រ៉ឺឡាទីបដែល $a>1, X>0$។ $k$ ជាចំនួនគត់រ៉ឺឡាទីបមិនអវិជ្ជមាន និង
$c_j$ ជាចំនួនគត់រ៉ឺឡាទីបដែល $0\le c_j<a$ ចំពោះ $j=0,1,\ldots,k$។
បង្ហាញថា $X$ អាចសរសេរបានមួយបែបគត់ជារាង $X=\sum_{j=0}^{k}c_ja^j$។

VI. (២០ពិន្ទុ) រង្វង់មួយមានផ្ចិត $O$ និងកាំ $R$ ចារឹកក្រៅត្រីកោណ $ABC$ មួយដែលមានបរិមាត្រ $2p$។ ត្រីកោណ $ABC$ នេះចារឹកក្រៅរង្វង់មួយទៀតដែលមានផ្ចិត $I$ និងកាំ $r$។
បង្ហាញថា $4R+r=p\left(\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2}\right)$។

សុខ ពិសិដ្ឋ - Sok Piseth Page Facebook.com/TeacherSokPiseth pisethsok.wordpress.com plus.google.com/+PisethSok_SPS

# ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

## ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា រូបវិទ្យា ថ្នាក់ទី ៩ និងទី ១២

## សម័យប្រឡង: ០១.០៤.២០១០

## អត្រាកំណែគណិតវិទ្យា ថ្នាក់ទី ១២ លើកទី ២ ថ្ងៃទី ០៣.០៤.២០១១

## រយៈពេល ១៨០នាទី ពិន្ទុ ១០០

I. (១០ពិន្ទុ) រកលេខ $x$ និង $y$ ដោយដឹងថាក្នុងទ្រង់ទីមួយៗមានចំនួនគូនមាន់ស្មើៗគ្នា :

គេត្រូវរកលេខ $x$ និង $y$ ក្នុងប្រព័ន្ធរាប់គោលដប់ដើម្បីឱ្យចំនួន $\overline{7y38x5}$ ចែកដាច់នឹង 99 ។

គេមាន $\gcd(9,11) = 1$

ដើម្បីឱ្យ $\overline{7y38x5}$ ចែកដាច់នឹង $99 = 9\times 11$ លុះត្រាតែ

$7 + y + 3 + 8 + x + 5 \equiv 0 \pmod 9$ និង $5 + 8 + y - x - 3 - 7 \equiv 0 \pmod{11}$ ២ ពិន្ទុ

$\Leftrightarrow (x + y \equiv 4 \pmod 9) \wedge (-x + y \equiv -3 \pmod{11})$

$\Leftrightarrow (x + y = 9m + 4) \wedge (-x + y = 11n - 3)$ ២ ពិន្ទុ

ដោយ $(0 \le x, y \le 9) \Rightarrow 0 \le x + y \le 18, -9 \le -x + y \le 9$ នោះគេទាញបាន : ២ ពិន្ទុ

$(x + y = 4) \wedge (-x + y = -3), (x + y = 4) \wedge (-x + y = 8),$ ២ ពិន្ទុ

$(x + y = 13) \wedge (-x + y = -3), (x + y = 13) \wedge (-x + y = 8)$

ដូចនេះ $x = 8, y = 5$ ២ ពិន្ទុ

II. (១០ពិន្ទុ) ស្រាយបញ្ជាក់ចម្ងាយពីចំណុច $M_0(x_0, y_0)$ ទៅអ័ក្សទាំងពីរនៃតម្រុយអរតូណរម៉ាល់ :




ដោយ $x_0$ ជាតួចែករួមធំបំផុតនៃ $a$ & $b$ ហើយ $y_0$ ជាតួចែករួមធំបំផុតនៃ $A = \alpha a + \beta b$ & $B = \lambda a + \mu b$

នោះគេបាន : $(x_0|a \wedge x_0|b) \Rightarrow x_0|(\alpha a + \beta b) = A$ និង $(x_0|a \wedge x_0|b) \Rightarrow x_0|(\lambda a + \mu b) = B$

ដូចនេះ $x_0|y_0$ (1) ២ ពិន្ទុ

ម្យ៉ាងទៀត $y_0|A = \alpha a + \beta b \Rightarrow y_0|(\alpha\mu a + \beta\mu b)$

$y_0|B = \lambda a + \mu b \Rightarrow y_0|(\beta\lambda a + \beta\mu b)$

គេបាន $y_0|(\alpha\mu - \beta\lambda)a = a$ ព្រោះ $\alpha\mu - \beta\lambda = 1$ ២ ពិន្ទុ

